**TKI0756**

# សម្ភាសន៍ជាមួយ ផាន់ សុខន ភេទប្រុស អាយុ៥៣ឆ្នាំ

## មុខងារៈ យោធាកងពល២៥០

## រស់នៅភូមិហាន់ទា ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សេង គន្ធី

**Audio Video: 01:18:38**

**៤៤ទំព័រ**

គន្ធី ៈ ថ្ងៃនេះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ។ មុនដំបូងពួកខ្ញុំសាកសុំណែនាំខ្លួនពួកខ្ញុំសិន ។ ខ្ញុំឈ្មោះ សេង គន្ធី ហើយគាត់នេះឈ្មោះ គីម ស្រួយសុខវិសាល ជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាបុគ្គលិកនៅកន្លែងនេះ ដែលអ៊ំមើលទស្សនាវដ្ដីនេះណា ហើយពួកខ្ញុំមកសុំចង់សុំសម្ភាសន៍អ៊ំ ថាថតក្នុងCamaraដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ អ៊ំយល់ថាម៉េចដែរ?

សុខន ៈ គ្មានយល់ថាម៉េចទេ ។

គន្ធី ៈ អនុញ្ញាតិឲ្យពួកខ្ញុំថតទេ?

សុខន ៈ គ្មានអី បើមកថតហើយ មិនដឹងពួកខ្ញុំថាម៉េចដែរ ។

គន្ធី ៈ អត់អីទេ សុំអនុញ្ញាតិថតទុក អត់អីទេ?

សុខន ៈ គ្មានអីទេ ។

គន្ធី ៈ បើសិនជារឿងអ៊ំពួកខ្ញុំចង់ចុះក្នុងទស្សនាវដ្ដី ដូចថាអប់រំដល់ក្មេងៗជំនាន់ក្រោយបានរៀនសូត្រជាប្រវត្តិសាស្ត្រ ហើយអ្នកស្រាវជ្រាវទុកពីរបបខ្មែរក្រហម គេចង់សិក្សា អ៊ំយល់ទាស់ទេ? អត់ថាអី អនុញ្ញាតិទេ?

សុខន ៈ គ្មានថាអី ។

គន្ធី ៈ មុនដំបូងចង់ស្គាល់ឈ្មោះអ៊ំសិន?

សុខន ៈ ខ្ញុំឈ្មោះ ផាន់ សុខន ។

គន្ធី ៈ ផាន សុខន?

សុខន ៈ ផាន់ ។

គន្ធី ៈ ផាន់ សុខន?

សុខន ៈ សុខន ។

គន្ទី ៖ អ៊ំអាយុប៉ុន្មានហើយឥឡូវ?

សុខន ៖ ៥៣ឆ្នាំ ។

គន្ទី ៖ អ៊ំមានចាំ អ៊ំកើតនៅខែឆ្នាំណាដែរ?

សុខន ៖ គ្មានទេ ។

គន្ទី ៖ អត់ចាំទេ?

សុខន ៖ បាទ!

គន្ទី ៖ អ៊ំកើតនៅភូមិនេះដែរ?

សុខន ៖ នៅហ្នឹង ។

គន្ទី ៖ បច្ចុប្បន្នរស់នៅភូមិនេះ ភូមិនឹងឈ្មោះអីដែរ?

សុខន ៖ ភូមិហាន់ទា ។

គន្ទី ៖ ភូមិហាន់ទា ឃុំ?

សុខន ៖ កំពែង ។

គន្ទី ៖ ស្រុក?

សុខន ៖ ស្រុកគីរីវង់ ខេត្តតាកែវ ។

គន្ទី ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់?

សុខន ៖ ខ្ញុំបងប្អូន៤នាក់ ។

គន្ទី ៖ ៤នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

សុខន ៖ ប្រុស៣ ស្រី១ ។

គន្ទី ៖ អ៊ំកូនទីប៉ុន្មាន?

សុខន ៖ ខ្ញុំបងគេ ។

គន្ទី ៖ ឥឡូវនេះអ៊ំមានកូនប៉ុន្មាននាក់ដែរ?

សុខន ៖ កូនតែ២ ។

គន្ទី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សុខន ៖ ស្រី១ ប្រុស១ ។

គន្ទី ៖ អ៊ំរៀបការឆ្នាំណា?

សុខន ៖ អឺ! អាការគ្មានចាំទេ ខ្ញុំមិនដែលគិតឆ្នាំណាៗ ការវាយូរពេកហើយ ។

គន្ទី ៖ រៀបការមុនខ្មែរក្រហម ឬក្រោយ?

សុខន ៖ ការជំនាន់ចុះមក ។

គន្ធី ៖ រៀបការប៉ុន្មានឆ្នាំហើយ?

ប្រពន្ធ ៖ ការ២៣ឆ្នាំហើយ ការឆ្នាំ៨០ះមក ។

គន្ធី ៖ ក្រោយខ្មែរក្រហម?

សុខន ៖ បាទ! ចុះមកពីលើ យើងបែកខ្មែរក្រហមហើយ ។

គន្ធី ៖ ចុះកាលមុនសម័យខ្មែរក្រហមនឹង ខ្ញុំនិយាយតាំងពីឆ្នាំ៧០មក តាំងពីរដ្ឋប្រហារសម្តេចឪ ។ កាលនឹងអ៊ំអាយុប៉ុន្មាន កាលសម្តេចឪ?

សុខន ៖ កាលនឹងអាយុជាប្រហែល១២ ១៣ ១៥ឆ្នាំ ។

គន្ធី ៖ អ៊ំនៅណា?

សុខន ៖ នៅផ្ទះ ធ្វើស្រែចំការជាមួយម៉ែឪ អត់មានទៅណាជំនាន់ទាហាន ។

គន្ធី ៖ ឪពុកម្តាយអ៊ំធ្វើអីដែរ?

សុខន ៖ គាត់គ្មានធ្វើអីទេ គាត់ធ្វើស្រែធ្វើចំការនេះដែរ ។

គន្ធី ៖ ជាមួយគ្នានៅភូមិឃុំនេះដែរ?

សុខន ៖ បាទ! នៅនឹង ម្តាយក៏នៅនឹង ឪពុកក៏នៅនឹង ។

គន្ធី ៖ ចុះបងប្អូនអ៊ំ ៣-៤នាក់ទៀត?

សុខន ៖ បងប្អូន៤នាក់នឹង ១-២នៅនឹង ហើយអា២ទៀតគេនៅស្រុកអន្លង់វែង នោះ ។

គន្ធី ៖ នៅកំពតវិញ?

សុខន ៖ បាទ! នៅខាងកំពត ។

គន្ធី ៖ គាត់ធ្វើអីដែរ?

សុខន ៖ គេមានប្រពន្ធនៅនឹង ។

គន្ធី ៖ អ្នកណាគេមានប្រពន្ធខ្លះដែរ?

សុខន ៖ គេរកស៊ីធ្វើស្រែ ធ្វើចំការ អាប្អូនៗនៅនឹង ។

គន្ធី ៖ គាត់មានប៉ុន្មាននាក់ដែរ ដែលរៀបការរួច?

សុខន ៖ ការហើយទាំងអស់ ។

គន្ធី ៖ នៅសល់តែអ៊ំទេ?

សុខន ៖ កូននឹង ។

គន្ធី ៖ ខ្ញុំនិយាយតែបងប្អូនអ៊ំ?

សុខន ៖ បងប្អូនការហើយអស់ហើយ ។

គន្ធី ៖ កាលឆ្នាំ៧០ ?

សុខន ៖ ទើបនឹងការ កាលយើងឥឡូវៗនេះ ការក្រោយៗខ្ញុំ ។

គន្ធី ៖ កាលឆ្នាំ៧០នឹងពួកគាត់នៅណាដែរ?

សុខន ៖ នៅមូលគ្នាទាំងអស់ ។

គន្ធី ៖ នៅក្នុងផ្ទះអ៊ំមានសមាជិក មានឪពុកម្ដាយមានបងប្អូនអ៊ំ៤នាក់ទាំងអ៊ំ ហើយនៅនេះទៅធ្វើស្រែចំការ?

សុខន ៖ បាទ!

គន្ធី ៖ គាត់អត់មានធ្វើអីផ្សេងទៀតទេ ក្រៅពីស្រែចំការ?

សុខន ៖ អត់ទេ សុទ្ធតែនៅស្ទើរៗទាំងអស់ ។

គន្ធី ៖ អ៊ំកាលឆ្នាំ៧០នឹង ពេលសម្ដេចសីហនុ ពេលរដ្ឋប្រហារគាត់ នៅភូមិអ៊ំ ខ្មែរក្រហមចូលនៅឆ្នាំណាដែរ?

សុខន ៖ រឿងអីចឹង គ្មានសូវចេះដឹងនឹងគេទេ នៅស្ទើរៗកាលនឹង ។

គន្ធី ៖ កាលនឹងមុនៗគេទម្លាក់សម្ដេចឪ ឬមួយក៏ក្រោយមក?

សុខន ៖ កាលនឹងមិនដឹងស្អីៗ ឃើញគេបញ្ចេញបញ្ចូលមានអាវខ្មៅខោខ្មៅ តិចឃើញទាហានមកអីចឹងទៅ ។

គន្ធី ៖ គេចូលមកដំបូងមានគ្នាប៉ុន្មាននាក់?

សុខន ៖ គ្នាគេមកម៉ាក្រុមៗ១២នាក់ ២០នាក់គេចូលមកក្នុងភូមិនឹង ។

គន្ធី ៖ គេមានប៉ែកអីទេ ចូលមកធម្មតា យើងមិនដែលឃើញគេពាក់ខ្មៅ ស្លៀកពាក់ខ្មៅ?

សុខន ៖ គេគ្មានធ្វើអីយើងទេ គ្រាន់តែគេមករកទាហាន ហើយយើងឃ្វាលគោ ខ្ញុំនៅស្ទើរៗដឹងថាមកពីរៀនឃ្វាលគោ ។

វិសាលៈ អីចឹងអ៊ំបានទៅរៀនសូត្រដែរ ពេលនៅក្មេង?

សុខន ៖ បាទ!រៀន ខ្ញុំរៀនបានត្រឹមថ្នាក់ទាបដែរ ថ្នាក់ទី១០ ។

គន្ធី ៖ នៅសាលាណា?

សុខន ៖ វត្តកំពែង ។

វិសាលៈ សាលាវត្ត?

សុខន ៖ ពីដើមទី១០ ។

វិសាលៈ បងប្អូនអ៊ំទៅរៀនអស់គ្នា?

សុខន ៖ បាទ! រៀនទាំងអស់ ។

គន្ធី ៖ បងប្អូនអ៊ំបានរៀនទាំងអស់គ្នា?

សុខន ៖ បាទ! ដល់ចុះមកពីលើបានគេឈប់រៀនហើយ អាប្រុសៗ នៅមីពៅមួយចេះតែម៉ែឲ្យរៀនៗ ដល់គិរី ។

វិសាលៈ អ៊ំឈប់រៀនឆ្នាំណា?

សុខន ៖ ខ្ញុំឈប់រៀនកាលរដ្ឋប្រហារនឹងម៉ង ។

វិសាលៈ មូលហេតុអីបានឈប់ទៅ?

សុខន ៖ ចុះបើឡានទម្លាក់ វវល់តែបាញ់ផ្លោង ។

ប្រពន្ធ ៖ ដល់ចេះ ស្រុកយើងនៅពេលរដ្ឋប្រហារមកបិទសាលារៀន អត់មានសាលាមានអីទេ ស្រុកយើងនឹងអីចឹង ។

វិសាលៈ បិទសាលា រដ្ឋប្រហារភ្លាម បិទភ្លាម?

សុខន ៖ បាទ! បិទ គ្មានគ្រូ គ្មានអីទេ គ្រូរត់ទៅភ្នំពេញអស់ហើយ គ្រូភ័យ ។

វិសាលៈ គ្រូរត់ទៅភ្នំពេញអត់មានគ្រូ គ្រូរត់ចូលភ្នំពេញ?

សុខន ៖ បាទ! រត់ទៅភ្នំពេញអស់ ។

វិសាលៈ ដោយសារទម្លាក់គ្រាប់បែក?

សុខន ៖ បាទ! គេខ្លាចអាពតផង ។

គន្ធី ៖ កាលនឹងមានអាពតដែរ?

សុខន ៖ មាន ។

គន្ធី ៖ មានអាពតចូលមក?

សុខន ៖ បាទ! មានមួយៗ គេមិត(រត់) ទៅភ្នំពេញអស់ ។

គន្ធី ៖ ចុះប៉ុល ពតចូលមក គ្រូបង្រៀនខ្លាចអីចឹង ចុះដូចអ៊ំអត់ទៅណាទៅណីដែរ?

សុខន ៖ អត់ទៅណា ខ្ញុំនៅស្ទើរៗ មើលតែគោ ។

វិសាលៈ ឈប់រៀន ធ្វើស្រែ មើលគោ?

សុខន ៖ បាទ!

គន្ធី ៖ ហើយដល់ពេលចូលមកអីចឹងទៅ កាលនឹងមានរឿងអី ដែលនៅក្នុងភូមិអ៊ំដូចថាលោកគ្រូៗ គាត់ ទៅភ្នំពេញនឹង អ៊ំមានប្រសាសន៍មិញថាឡានហោះទម្លាក់គ្រាប់បែកអីចឹង?

សុខន ៖ បាទ! មាន ។

គន្ធី ៖ ហើយធ្វើម៉េចទៅអ៊ំ ពេលនឹង?

សុខន ៖ ពេលនឹងយើងរត់ឡើងព្រៃទៅ រត់ទៅភ្នំគេកៀរឲ្យយើងទៅភ្នំ យៀកុង យួនយៀកុង ។ យើងដើរជីកត្រង់សេរពេញព្រៃភ្នំ នៅពួន ។

គន្ធី ៖ អត់នៅផ្ទះភូមិកើតទេ?

សុខន ៖ បាទ! នៅភូមិអត់មាននៅកើតទេ ។

គន្ធី ៖ ចុះម៉េចអ៊ំ អ៊ំមានប្រសាសន៍ថាយួនធៀវគឺ អ៊ំមានប្រសាសន៍ថាយួនគេកៀរយើងទៅ?

សុខន ៖ បាទ!

គន្ធី ៖ ចុះកាលនឹងមានអ្នកណាគេខ្លះ ដល់ពេលមានខ្មែរក្រហមផង មានយួនផង?

សុខន ៖ បាទ!

គន្ធី ៖ ម៉េចក៏គេចូលមកក្នុងទឹកដីខ្មែរ?

ប្រពន្ធ ៖ ចេះដល់ពេលយួនចូលមក ខ្មែរក្រហមរត់បាត់អស់ហើយ ។

គន្ធី ៖ កាលនឹងម៉េចទៅអ៊ំ?

សុខន ៖ ដល់ពេលយួនចេញមក បានវាមកទៀតម៉ាភ្លែតៗ ។

គន្ធី ៖ កាលនឹងអ្នកណាគេ ដូចមានរឿងជាមួយគ្នាដែល កាលនឹងបានថាគេចូលមក?

សុខន ៖ រឿងតែគ្នាគេ... ។

គន្ធី ៖ កាលនឹងខ្មែរក្រហមវៃជាមួយយួន?

សុខន ៖ វៃជាមួយយួន ។

គន្ធី ៖ ហើយកាលនឹងម៉េចទៀតទៅ អ៊ំថាអ្នកណាគេកៀរទៅ?

សុខន ៖ អានឹងដល់ពេលនឹងគេប្រមូលផ្តុំៗទៅកងព្រលិត ចេញប្រមូលយុវជន ប៉ុលពតនឹងគេប្រមូលយើងអ្នកកម្លាំងៗយុវជនប្រមូលទៅនៅតាមកងៗព្រលិត ទៅនៅកំពង់វត្តលិច ។

គន្ធី ៖ កាលនឹងពូមានប្រសាសន៍ថា ពេលឡានទម្លាក់គ្រាប់បែកពីណាគេកៀរអ៊ំទៅ នាំប្រជាជនទៅកៀរ?

សុខន ៖ អានឹងបើភូមិគេៗអត់ឲ្យយើងនៅ ដល់រួចគេអាពតនឹងមក គេអត់ឲ្យយើង គេឲ្យប្រមូលផ្តុំទៅនៅតាមកងមូលគ្នាអស់ ម៉ាស្រុកគិរីវង់ ។

គន្ធី ៖ អាពតកៀរមិនមែនយួនកៀរទៅ?

សុខន ៖ មិនទេ អាពត គេឲ្យនៅមូលគ្នាធ្វើការយើងជីកប្រឡាយ ជីកព្រែកអីចឹង ។

គន្ធី ៖ ពេលទៅដល់គេឲ្យយើងទៅធ្វើការ?

សុខន ៖ បាទ! ឲ្យយើងធ្វើការ ហើយចាស់ប៉ុនណា អង្ករ៤-៥កំប៉ុង ទឹកឡើងរ៉ាវ ចេះនាំគ្នាហូបទៅ សុទ្ធតែទឹក ។

គន្ធី ៖ ហើយកាលនឹងបែកភ្នំពេញហើយនៅ?

សុខន ៖ បែកហើយ ។

គន្ធី ៖ កាលគេកៀរអ៊ំទៅ?

សុខន ៖ បែកហើយ ។

គន្ធី ៖ ចុះមុនបែកនឹង កៀរអ៊ំទៅធ្វើអីដែរ?

សុខន ៖ មុនបែកនឹង ទៅជីកព្រែកជីកប្រឡាយ ។

គន្ធី ៖ អានឹងការងារខ្លួនយើង?

សុខន ៖ ការងារគេប្រើ ការងារគេមូលគ្នា គ្មានអ្នកណានៅជាមួយម៉ែឪនៅផ្ទះ ។ បើសិនជាម៉ែឪក៏គាត់ប្រមូលផ្តុំគ្នាគាត់ គេចាត់ឲ្យគាត់ធ្វើនេះធ្វើនោះមានមុខងារដូចគ្នា ។ ដូចឪខ្ញុំវ៉ាន់គេចាត់ឲ្យគាត់ដុតធ្យូង បរទេះគោជីកធ្យូងនៅនឹងភ្នំ ។

គន្ធី ៖ ពេលទម្លាក់សម្តេចឪហើយ ពេលយួនចូលមកដល់ ខ្មែរក្រហមធ្វើម៉េច ខ្ញុំតាមកន្លែងនឹងអត់ទាន់ ដូចថាពេលឡានហោះទម្លាក់គ្រាប់បែកមក យួនចូលមកដល់ ហើយខ្មែរក្រហមធ្វើម៉េចទៀត ពេលនឹងខ្ញុំតាមអត់ទាន់កន្លែងនឹង?

សុខន ៖ មានធ្វើម៉េចទៀត ដល់បែកអស់គេកៀរយើងមិត(រត់) ទៅស្រុកលើ ។

គន្ធី ៖ គេនឹងអ្នកណាគេដែរ?

សុខន ៖ អាពតនឹង ។

គន្ធី ៖ ហើយចុះយួនធ្វើម៉េច?

សុខន ៖ យួននៅពេញនឹង គេកៀរឲ្យទៅនៅ យួនគេដេញអាពត ដល់គេតាមយើងទាន់ គេឲ្យយើងមកវិញមក យួននឹង គេឲ្យយើងមកស្រុកមកភូមិវិញមក ។

គន្ធី ៖ ហើយដល់ពេលហើយ អ៊ំគេតាមមកទាន់ ម៉េចអ៊ំមកភូមិវិញ ហើយម៉េចទៀត?

សុខន ៖ បាទ! គេឲ្យមកនៅភូមិវិញ មានម៉េច មកធ្វើស្រែចំការ ស្រែរួមគ្នា ស្រែសាមគ្គី ហើយអាអ្នកអត់គោយើងជួយធ្វើគ្នា អាអ្នកមានគោជួយធ្វើអាអ្នកអត់រួមគ្នា ។

គន្ធី ៖ ហើយបន្ទាប់មកម៉េចទៀត?

សុខន ៖ គេចាប់អាមេៗ គេចាប់យកទៅបាន យួនអាគេចាប់អាមេៗនឹង ។

គន្ធី ៖ មេអីគេ?

សុខន ៖ ប្រធានកង ប្រធានយុវជនអី ប្រធានឃុំអីនឹង ។

គន្ធី ៖ កាលនឹងមានប្រធានកង ប្រធានឃុំ?

សុខន ៖ នៅ យួនតាមទាន់វាចាប់ ហើយជំនាន់នឹងយើងមានពាក់ត្រនាប់ជើង សុទ្ធត្រនាប់ជើងក្រវាត់ មើលឃើញស្នាមក្រវ៉ាត់វាចាប់ទៅ ។

វិសាលៈ អ៊ំនិយាយនឹង និយាយពេលបែកហើយ?

សុខន ៖ បាទ!

វិសាលៈ អីចឹងហេតុការណ៍នឹងគឺបែក៧៩ហើយ?

សុខន ៖ និយាយអាគេកៀរយើងទៅៗ គេកៀរទៅយើងចុះមកវិញ មិនទាន់បែកទេអានឹង វាទៅតាមយើងទាន់ដល់ស្រុកលើ គេកៀរយើងឲ្យមកវិញ គេឲ្យមកវិញ ។

វិសាលៈ ពេលនឹង ពេលដែលកងទ័ពវៀតណាមចូលមកច្រើននឹង?

សុខន ៖ បាទ! ហ្នឹងហើយ ។

វិសាលៈ ពេល៧៩?

សុខន ៖ ហើយអាពតចេះកៀរយើងទៅ វាមិនឲ្យយើងនៅ ។

គន្ធី ៖ អ៊ំខ្ញុំចង់សួរបករបបខ្មែរក្រហម កាលនឹងអត់ទាន់ចូលរបបខ្មែរក្រហមទេ អត់និយាយថាខ្មែរក្រហមចូលដល់ភ្នំពេញ ខ្ញុំនិយាយពេលសម្តេចសីហនុ គាត់ត្រូវគេទម្លាក់រដ្ឋប្រហារលន់ នល់ទម្លាក់រដ្ឋប្រហារ ។ ហើយកាលនឹង ខ្មែរក្រហមចូលមកភូមិអ៊ំគេធ្វើម៉េចដែរ ក្នុងភូមិអ៊ំ កុំអាលទាន់និយាយវៀតណាម?

សុខន ៖ កាលគេចូលមក ខ្ញុំគេឲ្យនៅទ័ព កូនទៅទាំងអស់នៅតែម៉ែឪ ខ្ញុំក៏រត់ទៅនឹងគេឯងដែរ រត់ទៅមុខរហូត ។

គន្ធី ៖ កាលនឹងឆ្នាំណា?

ប្រពន្ធៈ អានឹងមុនៗអាពត ។

គន្ធី ៖ មុនអាពតប្រហែលប៉ុន្មានឆ្នាំ?

សុខន ៖ មុនរដ្ឋប្រហារ មុនបែកឥឡូវ ប្រហែលយួនបុកយើងចេះរត់ទៅនឹងគ្នា អាបាក់ទ័ពចេះទៅយួនគេដេញ ។

វិសាលៈ គន្ធីគាត់ចង់សុំសួរអ៊ំហេតុការណ៍ បន្ទាប់ពីរដ្ឋប្រហារលន់ នល់មក រដ្ឋប្រហារលន់ នល់ឆ្នាំ៧០ គាត់ចង់សួរអ៊ំមានព្រឹត្តិការណ៍អីខ្លះ ពីចន្លោះ៧០ដល់៧៥?

សុខន ៖ គ្មានទេ ខ្ញុំគ្មានស្អីៗ ធ្វើអីៗ

វិសាលៈ អ៊ំមិញមានប្រសាសន៍ថា មុនបែកភ្នំពេញ៧៥នឹង គេមានជម្លៀសទៅណាមួយ?

សុខន ៖ អូ! អានឹងដល់នេះគេឲ្យយើងទៅប្រមូលផ្តុំនឹងៗ

គន្ធី ៖ អានឹងអត់ទាន់បែកភ្នំពេញទេ?

សុខន ៖ បាទ! នៅ ដល់ទៅបានតិច បានបែកៗ

វិសាលៈ អីចឹងបានន័យថា ប្រហែលជាចន្លោះ៧០ដល់៧៥នឹង អ៊ំត្រូវបានគេបញ្ជូនទៅកន្លែងណាមួយ ហើយដល់ពេលនៅបានតិចទៅ បានបែកភ្នំពេញ?

សុខន ៖ បាទ! ហ្នឹងហើយ

វិសាលៈ អ៊ំអាចសុំជួយប្រាប់ពួកខ្ញុំពីគេជម្លៀសនឹង ពីណាគេជម្លៀសទៅឆ្នាំណា ជួយប្រាប់ផងបានទេអ៊ំ?

សុខន ៖ អានឹងគេជម្លៀសយើងទៅ អាអ្នកនៅនឹងប្រធានៗកងនៅភូមិ គេមិនឲ្យយើងនៅម៉ង យើងកម្លាំងយុវជន-នារី គេឲ្យទៅនៅមូលគ្នានៅកំពង់វត្តបណ្តេញៗ នៅធ្វើការរួមនឹងជីកព្រែកជីកប្រឡាយ ប្រព័ន្ធស្រែ អាណាជាន់រហាត់ទឹកៗ អាណាលើកប្រព័ន្ធភ្លឺៗទៅៗ

គន្ធី ៖ ហើយចុះអ៊ំ?

សុខន ៖ គ្មានគោគ្មានអីទេ អូសតែមនុស្សនង្គ័លៗមួយគ្នា៣នាក់ ម្នាក់កាន់យាម ២នាក់អូសៗ

គន្ធី ៖ ហើយកាលខ្មែរក្រហមចូលមកភូមិអ៊ំភ្លាមៗ គេឲ្យអ៊ំ ប្រជាជនទាំងអស់នឹងម៉េចដែរ ដូចថាតាំងពីមុន គេឲ្យអ៊ំទៅធ្វើការភ្លាមៗ ឬមួយក៏គេថាមានអ្នកចូលរួមបដិវត្តជាមួយគ្នាដែរ?

សុខន ៖ អឺ! កាលនឹងគេមិនទាន់ឲ្យទៅភ្លាមៗ កាលនឹងគេឲ្យនៅជួយធ្វើស្រែធ្វើអីជាមួយចាស់ៗ ដល់យូរៗថា កុំទុកឲ្យនៅគេឲ្យទៅមូលគ្នាៗ តែនេះគេអត់ឲ្យខ្ញុំទៅទេ គេឲ្យនៅធ្វើស្រែធ្វើអីជាមួយកងចាស់ៗនឹង គេថាទេ គេមិនឲ្យទុកនៅទេ មេភូមិ តាហ៊ានអីនឹង គេថាកុំទុកយុវជនទៅមុខទៅបានពូគង់គាត់ឲ្យខ្ញុំទៅមុខៗ

គន្ធី ៖ គេឲ្យទៅមុខទៅធ្វើអីដែរ?

សុខន ៖ ទៅអាកន្លែងកំពង់វត្តបណ្តេញនឹង គេទៅមូលគ្នា ប្រមូលគ្នាៗ

គន្ធី ៖ កាលនឹងគេអត់ទាន់មានប្រកាសថាជ្រើសរើស ដូចថាយុវជនអ្នកមានកម្លាំងពេញចូលរួមបដិវត្ត គេអី?

សុខន ៖ កាលនឹងគេរើសហើយៗ

គន្ធី ៖ គេមានដើរប្រកាសតាមភូមិ?

សុខន ៖ គេប្រាប់អីចឹង គេមិនទុកយុវជន យុវនារី គេឲ្យទៅម៉ុំ ។

គន្ធី ៖  ចុះអ៊ំមានចូលរួមដែរ បដិវត្តនឹង ចូលរួមបដិវត្តនឹងគេ?

សុខន ៖ ទៅធ្វើការធ្វើងារនឹងគេ គេហៅទៅជីក១ព្រែក ជីកប្រឡាយ ។

គន្ធី ៖  រយៈពេលប៉ុន្មានដែរ ដែលអ៊ំធ្វើការនៅនោះ ប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

សុខន ៖ មិនដឹងប៉ុន្មានខែហ្នឹង  ទៅនៅនោះបានប្រហែលម៉ាឆ្នាំជាងដែរ  នៅចេញពីកងព្រលិតទៅនៅឈ្លបនឹង ។ ដល់គេបែក ។

គន្ធី ៖  អ៊ំធ្វើឈ្លបនៅនឹង?

សុខន ៖ បាទ! ទៅនៅឈ្លប គេឲ្យទៅនៅឈ្លប ដល់យើងខ្សែរយៈមិនស្អាត រតាតរតាយគេដកយើងឲ្យមកវិញ ឲ្យមកកងយុវជនវិញ មកជីកប្រឡាយ ជីកព្រែកទៀត ។ ដល់ពេលគេរើសទ័ពទៅមុខ គេរើសទៅទៀត គេឲ្យទៅទៀត ចេះទៅតាមតែគេ ។

គន្ធី ៖  អ៊ំធ្វើបានរយៈពេលប៉ុន្មាន?

សុខន ៖ ឈ្លបនឹងបានកន្លះឆ្នាំដែរ ។

គន្ធី ៖  កន្លះឆ្នាំ?

សុខន ៖ បាទ!

គន្ធី ៖  ឆ្នាំណាដែរ អ៊ំមានចាំទេ?

សុខន ៖ អត់ទេ ខ្ញុំអត់ចេះចាំ ។

គន្ធី ៖  ប្រហែលជាបែក យើងចូលមកចូលក្នុងសម័យខ្មែរក្រហមយូរដែរ?

សុខន ៖ ទៅនៅឈ្លបនឹងទៅបានតិច បែកភ្នំពេញ ។

វិសាលៈ អីចឹងធ្វើឈ្លបមុនបែកភ្នំពេញ?

សុខន ៖ បាទ! ចូលគេប្រមូលនឹង បានទៅបានតិចបានបែកភ្នំពេញ ។

វិសាលៈ តាមអ៊ំមានប្រសាសន៍នឹង គឺ ពូគង់ អ្នកហៅអ៊ំទៅកន្លែងមួយ គឺវត្តកំពង់ប្រដេញ?

សុខន ៖ កំពង់វត្តបណ្ដេញ ។

វិសាលៈ កំពង់វត្តដេញ?

សុខន ៖ បណ្ដេញ ។

វិសាលៈ ហើយអ៊ំនៅនឹងជាងម៉ាឆ្នាំ អ៊ំមានប្រសាសន៍មិញ?

សុខន ៖ នៅអានឹងវាបានយូរដែរ ។

វិសាលៈ នៅនឹងធ្លាប់ធ្វើឈ្លប ប្រហែលកន្លះឆ្នាំដែរ?

សុខន ៖ ហើយដល់ហើយបានគេរើសកម្លាំងទៅធ្វើឈ្លប បានជិតកន្លះ ។

វិសាលៈ កន្លះឆ្នាំ អាចថាកន្លះឆ្នាំធ្វើការ កន្លះឆ្នាំទៀតធ្វើឈ្លប?

សុខន ៖ បាទ! បានម៉ាឆ្នាំ ។

វិសាលៈ ពួកគ៉ នឹងត្រូវម៉េចនឹងអ៊ំ?

សុខន ៖ ពួកគ៉ គេនៅប្រធានកងនៅស្រុកនឹង មេកងស្រុកនៅនឹង ។

វិសាលៈ ប្រធានកងក្នុងស្រុក?

សុខន ៖ ហ្នឹង ។

វិសាលៈ គាត់សព្វថ្ងៃនៅណា?

សុខន ៖ ឥឡូវងាប់ហើយ វាមិនហ៊ាននៅ វាទៅនៅស្រុកវាចាញ់ងាប់ហើយ ស្លាប់អស់ ។

គន្ធី ៖ កាលធ្វើឈ្លបនឹង ប្រធានឈ្លបអ៊ំឈ្មោះអី?

សុខន ៖ ស្លាប់អស់ ។

គន្ធី ៖ ឈ្មោះអីដែរ?

សុខន ៖ ឈ្មោះ តាឆ្លួន ពន្លៃ ។

គន្ធី ៖ តា?

សុខន ៖ តាឆ្លួន កើតនៅភូមិពន្លៃ ។

គន្ធី ៖ ហើយចុះមានអ្នកណាគេធ្វើឈ្លបជាមួយអ៊ំទៀតទេ?

សុខន ៖ ហើយនែក! ដាន, ហេននៅព្រៃរំដេង ។

វិសាលៈ មានអ្នកនៅរស់?

សុខន ៖ នៅរស់នៅ ដាន មួយ ហើយនឹង ហេន ព្រៃរំដេង ។

គន្ធី ៖ ដាន ធ្វើឈ្លបជាមួយអ៊ំដែរ?

សុខន ៖ គាត់ប្រធាន ។

គន្ធី ៖ ប្រធានឈ្លប?

សុខន ៖ បាទ!

គន្ធី ៖ នៅភូមិណាដែរ?

សុខន ៖ គាត់នៅភូមិអណ្តូងជ្រុង ។

គន្ធី ៖ ភូមិអណ្តូងជ្រុង ឃុំអីដែរ?

សុខន ៖ តាហេន នឹង គាត់ធ្វើទ័ពនៅឃុំកំពែង ដាន ។

គន្ធី ៖ បន្ទាប់ពីដានហើយពីណាគេទៀត ហេង?

សុខន ៖ ហេន!

គន្ធី ៖ ហេន គាត់ជាអីដែរ?

សុខន ៖ គាត់នៅឈ្លបជាមួយខ្ញុំដែរ ប៉ុន្តែគាត់ប្រធានខ្ញុំ ។

គន្ធី ៖ ចុះ ដាន នឹង ប្រធានដែរ?

សុខន ៖ ដាន ក៏គាត់ប្រធានដែរ ប៉ុន្តែគេប្រធានអនុមេឃុំ ។

វិសាលៈ ចុះដាននឹង អាចថាប្រធានធំ ហើយ ហេន នោះមេអី?

សុខន ៖ បាទ!

វិសាលៈ ហើយតៗគ្នា?

សុខន ៖ បាទ! តគ្នា ។

គន្ធី ៖ ចុះកាលអីធ្វើឈ្លបនឹង ដូចថាគេមានណែនាំអីធ្វើរបៀបម៉េចដែរ ការងារអីឈ្លប?

សុខន ៖ គេគ្មានណែនាំធ្វើម៉េចទេ គ្រាន់យប់ឡើងយើងទៅយាម ហើយយាមចេញក្រៅយាម១០០ ម៉ែត្រ ២០០ម៉ែត្រពីកន្លែង ហើយមកកាលនឹងអង្គរពោតក្រហម ។

គន្ធី ៖ យាមយ៉ាងម៉េចខ្លះ ការងារ?

សុខន ៖ យាមៗខ្លាចយួន ខ្លាចអីមក ។

គន្ធី ៖ ហើយការងារពីណាដល់ណាដែរ ថាពីម៉ោងថ្ងៃប៉ុន្មានម៉ោង?

សុខន ៖ ដល់ឈ្លប យើងលែងធ្វើយើងនាំប្រជាជនដើរទៅនេះ ទៅកាប់ព្រៃកាប់អីដាំនេះអីចឹង អាណាត្រូវនៅកន្លែងនៅ អាណាត្រូវទៅៗ ។

គន្ធី ៖ ចុះមានធ្វើអីទៀតទេ?

សុខន ៖ គ្មានទេ ។

គន្ធី ៖ ឈ្លបគេនឹង ដូចថាពេលយប់អីធ្វើការងារអីខ្លះដែរ?

សុខន ៖ ពេលយប់ដើរ ដើរយាម ចេញពីកន្លែងអស់ នៅតែយាម ។

គន្ធី ៖ យាមនៅកន្លែងណាដែរ?

សុខន ៖ យាមជុំវិញមន្ទីរឃុំយើងនេះ ទៅម៉ាយប់ត្រង់នេះម៉ាយប់ត្រង់នោះចេះតែដើរទៅ ។

គន្ធី ៖ ដល់ម៉ោងប៉ុន្មានដែរ យប់ៗអត់បានសម្រាន្តអីចឹង?

សុខន ៖ បានម៉ោង១០-១១ យើងមកកន្លែងវិញ អស់រវាងមនុស្សដើរ ។

គន្ធី ៖ អស់មនុស្សដើរ?

សុខន ៖ បាទ! អស់រវាងមនុស្សដើរ កណ្ដាលអាគ្រាតៗជាង ។

គន្ធី ៖ ហើយគេដាក់វេណគ្នាម៉េចដែរ ការងារឈ្លបនឹង?

សុខន ៖ ដាក់វេណគ្នា ។

គន្ធី ៖ ដូចថាប៉ុន្មានថ្ងៃ គេផ្លាស់ប្ដូរអីម៉េច?

សុខន ៖ តែគ្នាតិច ម៉ាយប់ម្នាក់ៗ ។

គន្ធី ៖ អ្នកធ្វើការជាមួយអឹប៉ុន្មាននាក់?

សុខន ៖ គ្នា៤នាក់ ៦នាក់ ។

គន្ធី ៖ មានអ្នកណាគេខ្លះដែរ?

សុខន ៖ អាហាង មួយនៅកំពង់សោម អាលួត មួយនៅស្រុកដាំបេង ហើយ អាឡៃហេង មួយមានប្រពន្ធនៅបានជាខ្មុល ។

វិសាលៈ ពួកគាត់ ក្រោយមកបានចូលធ្វើទាហានដូចជាអីដែរទេ ឬក៏ក្រោយមកលែងធ្វើជាអី ឬមួយជាប្រជាជនធម្មតាវិញ?

សុខន ៖ បាទ! ពួកនឹងដល់នេះ ពួៗគេមកយកទៅអស់រលីង នៅតែខ្ញុំបានជាគេបញ្ជូនមកទ័ព បែករគាត់រគាយអស់ ។

វិសាលៈ អីចឹងធ្វើឈ្លបនឹង គឺធ្វើតាំងពីមុនបែកភ្នំពេញទៀត?

សុខន ៖ បាទ!

វិសាលៈ ពេលបែកភ្នំពេញ ឈប់ធ្វើឈ្លបហើយ?

សុខន ៖ ឈប់ គេឲ្យមកនៅយុវជន ជីកព្រែកជីកប្រឡាយ ដល់ពេលជីកព្រែកជីកប្រឡាយ គេឲ្យទៅនៅធ្វើទ័ព ។

គន្ធី ៖ អឹយុវជននឹងជីកប្រឡាយនឹង ធ្វើនៅណាដែរ?

សុខន ៖ ពេញតែដី ម៉ាស្រុកគិរីវង់នឹងដើរពេញទាំងអស់ ។

គន្ធី ៖ ធ្វើអីខ្លះដែរ?

សុខន ៖ ជីកតែព្រែក ជីកតែប្រឡាយ ហើយលើកភ្លឺស្រែនឹង ។

គន្ធី ៖ ធ្វើការងារដូចថាប៉ុន្មាន ពីម៉ោងប៉ុន្មាន ពីព្រឹកដល់ល្ងាចអីចឹងយ៉ាងម៉េចដែរ?

សុខន ៖ ពីព្រហាមឡើង យើងធ្វើម៉ាថ្ងៃ ម៉ោង១១យើងឡើងទៅហូបបាយ ម៉ោង១ចុះវិញ ។

គន្ធី ៖ តាំងពីព្រឹកម៉ោងប៉ុន្មាន?

សុខន ៖ ម៉ោង១១ ។

គន្ធី ៖ ព្រឹកៗឡើង?

សុខន ៖ ពេលព្រឹកម៉ោង៦ ម៉ោង៧យើងចេញទៅហើយ ។

គន្ធី ៖ សមាជិកដែលធ្វើការជាមួយអ៊ំនឹងប៉ុន្មាននាក់ដែរ?

សុខន ៖ ធ្វើចេះបែកម៉ែត្រម៉ាកងៗគ្នាច្រើន២០-៣០នាក់ គេប្រធានកងគេមានត្រួតលើយើង ឧទាហរណ៍ ថាលើកភ្លឺ គេវាស់ឲ្យយើងម្នាក់ប៉ុន្មាន៥ម៉ែត្រៗ ហើយម៉ាម្នាក់៥វាស់ឲ្យតទៅទៀត ដល់ម៉ោង ។

គន្ធី ៖ ២០-៣០នាក់ដែរ?

សុខន ៖ បាទ! ២០-៣០នាក់ដែរ ។

គន្ធី ៖ ប្រធានអ៊ំឈ្មោះអីដែរ ប្រធានកង?

សុខន ៖ ប្រធាននឹង តាប៉ាល់ ។

គន្ធី ៖ ហើយអនុប្រធាន?

សុខន ៖ អនុប្រធាននឹង មិនមែន អាញៀប ទេ តាប៉ាល់ អនុប្រធានគេ ។ ប្រធានយុវជន កាលនឹងអក នឹង ដល់ប្រធានកងប៉ាល់ ។

គន្ធី ៖ ហើយចុះប្រធានក្រុម?

សុខន ៖ ប្រធានក្រុមគេសុទ្ធតែពួកចាស់ៗ ។

គន្ធី ៖ ឈ្មោះអីដែលប្រធានកងអ៊ំ?

សុខន ៖ តាប៉ាល់ ។

វិសាលៈ តើគាត់នៅរស់ទេ?

សុខន ៖ គាត់នៅរស់ស្រុកក្បាលកិន ។

គន្ធី ៖ ស្រុកក្បាលកាក?

វិសាលៈ ភូមិឃុំអីដែរ?

សុខន ៖ ភូមិបន្ទាយមាសខាងកើត ។

គន្ធី ៖ ឃុំអីដែរ?

សុខន ៖ ដឹងស្អីគេ ឃុំបន្ទាយមាសខាងកើតនឹងម៉ង ។

វិសាលៈ ភូមិឃុំដូចគ្នាទៀត?

សុខន ៖ ភូមិក្បាលកិន ។

គន្ធី ៖ ភូមិក្បាលកិន ឃុំបន្ទាយមាសខាងលិច ខាងកើត?

សុខន ៖ អឺ! ឃុំទូកមាស ។

គន្ធី ៖ ហើយស្រុកអីគេដែរ?

សុខន ៖ ស្រុកទូកមាស ។

គន្ធី ៖ នៅកំពត?

សុខន ៖ បាទ!

គន្ធី ៖ ចុះប្រធានយុវជនអ៊ំឈ្មោះអី?

សុខន ៖ តាអង ។

គន្ធី ៖ ហើយមានប្រធានក្រុមទេ?

សុខន ៖ ប្រធានក្រុម បន្ទាប់មក ប៉ាល់ គេប្រធានយើងបន្ទាប់ គេប្រើយើង ។

គន្ធី ៖ តាប៉ាល់ នឹង ប្រធានកង មេកង?

សុខន ៖ បាទ! ប្រធានកង មេកង ។

គន្ធី ៖ ចុះមេក្រុម?

សុខន ៖ មេក្រុមនឹង ទៅបាត់ឈឹងអស់ តែម ហ្នឹងងាប់ហើយ ។

គន្ធី ៖ ឈ្មោះអីដែរ?

សុខន ៖ តែម ងាប់បាត់ ។

គន្ធី ៖ ឈ្មោះ តែម ស្លាប់ហើយ?

សុខន ៖ ស្លាប់ ។

គន្ធី ៖ មានប្រធានអីទៀត អស់ហើយ?

សុខន ៖ បាទ!អស់ តែប្រធានកង ប្រធានក្រុមអស់ហើយ ។

គន្ធី ៖ ហើយដល់ពេលហើយ គេឲ្យអ៊ំធ្វើការងារនឹង ដូចថាក្រៅពីធ្វើការងារនឹងមានធ្វើអីផ្សេងៗទៀត ទ?

សុខន ៖ អត់មានទេ យើងដឹងតែដឹកព្រែក ដឹងដឹកព្រែក ជីកប្រឡាយជីកប្រឡាយ លើកភ្លឺស្រែដឹងថាលើកភ្លឺ អស់ចប់ពីនឹង គេឲ្យទៅម៉ាមុខសញ្ញាទៀតចេះទៅៗ ។

គន្ធី ៖ កាលពេលនឹងនៅភូមិអ៊ំ មានគេជម្លៀសប្រជាជនថ្មីមកទេ?

សុខន ៖ មានតើ ពួក១៧មេសា មកនៅពេញនឹង ។

គន្ធី ៖ គេជម្លៀសមកពីខាងណាដែរ?

សុខន ៖ ពីភ្នំពេញ ។

គន្ធី ៖ ពីភ្នំពេញមក?

សុខន ៖ បាទ! ប៉ុនមិនដឹងនៅស្រុកណាៗ ខ្ញុំអត់ដែលបាននៅសួរនឹងគេទេ ។

គន្ធី ៖ ហើយអ្នក១៧មេសានឹង ធ្វើការងារដូចថាគេឲ្យធ្វើការងារណាដែរ ឬក៏ធ្វើ?

សុខន ៖ ធ្វើជាមួយគ្នា បើយុវជនអ្នកណានៅលីវមកនៅជាមួយយើងអីចឹង ទៅនៅជាមួយយុវជននៅជាមួយគ្នា ជីកព្រែកជីកប្រឡាយដូចតែគ្នា ។

គន្ធី ៖ ចុះអ៊ំធ្វើការងារអីចឹង មានដែលជួបប្រទះរឿងរ៉ាវដូចឃើញ ធ្លាប់ឃើញហេតុការណ៍អីផ្សេងៗទេ?

សុខន ៖ អត់ទេ អត់ដែល ។

គន្ធី ៖ អត់ដែល?

សុខន ៖ បាទ!

គន្ធី ៖ ដូចថាឃើញដូចជា មានប្រជាជនមកថ្មី គាត់មកអីចឹងគាត់ម៉េចដែរ ការងារគាត់?

សុខន ៖ ការងារគាត់ គាត់ធ្វើខ្លាច ធ្វើមាំជាងយើងទៀត ។

គន្ធី ៖ ខ្លាចយ៉ាងម៉េចទៅអ៊ំ?

សុខន ៖ គ្នាខ្លាចគេវ៉ៃចោល គេវ៉ៃគ្នា១៧មេសា តែយើងមិនប្រឹងធ្វើ គេថាយើងខ្ទាំងៗគេវ៉ៃចោល ។

គន្ធី ៖ ម៉េចក៏គេខ្លាចអីចឹង ខ្លាចខ្មាំងម៉េចទៅអ៊ំ?

សុខន ៖ តែយើងធ្វើខុស វាសុទ្ធតែចោទយើងថាខ្មាំងហើយ ជំនាន់នឹង ឲ្យតែខុស ។

គន្ធី ៖ ខុសៗយ៉ាងម៉េច?

សុខន ៖ ដូចបងថ្លៃគាត់ គ្រាន់ធ្វើមិនខុសប៉ុន្មានទេ គេថាយើងអ្នកមាន គេយកទៅវ៉ៃចោល ឲ្យតែយើងនាយទុន អ្នកមានគេចាប់យកទៅវ៉ៃចោល កូននៅក្រហមៗ ។

គន្ធី ៖ ហើយធ្វើម៉េចបានគេដឹង គេចោទយើងអីចឹង?

សុខន ៖ មិនដឹងរឿងរបស់គាត់ គេដឹង ខ្ញុំរ៉ាន់ខ្លាចគេ ឲ្យតែគេប្រើដាក់ បើគាត់ស្មោរវិញ ឲ្យតែគេវាស់ម៉ែត្រហើយ ទុកគេនៅៗផ្ទះនោះគេនៅចាំ អ្នកណាគាត់ហើយឡើងទូក ទឹកថ្មើរៗនឹងអាវក្រហមម៉ាកំណាត់ៗ អានឹងគាត់ស្មោរធ្វើស្រែប្រាំងអី ទំលាប់ឲ្យតែគេវាស់ម៉ែត្រហើយទៅហើយ ។

គន្ធី ៖ អ៊ីខ្ញុំសួរបកទៅក្រោយ អ៊ំធ្វើឈប ដល់ពេលក្រោយមក អ៊ំធ្វើរយៈពេលកន្លះឆ្នាំនឹងម៉េចដែរការងារអ៊ំ?

សុខន ៖ គ្មានម៉េចទេ ខ្ញុំមនុស្សវាស្លូត គេមិនចេះធ្វើអី ប៉ុនខ្ញុំដឹងថាគេធ្វើបាប ។

គន្ធី ៖ គេធ្វើបាបម៉េចខ្លះ?

សុខន ៖ ដល់ពេលមកនៅយុវជនបានគេធ្វើបាប គេថាយើងអាមួយវាស្អប់ខ្ញុំវារាយការណ៍ នេះប្អូនវាលួចសាច់ជ្រូករលីងស៊ី វាអត់ធ្វើការ វាស៊ីមិនឆ្អែត អាប្អូនប្រធានកង-អនុប៉ាល់នឹង អាស៊ីមនឹង វាស៊ីមិនឆ្អែត វាលួចសាច់ជ្រូករលីងស៊ី គេចោទថាខ្ញុំ គេរាយការណ៍ថាខ្ញុំ ស្អីៗក៏ខ្ញុំ ដូចគេថាអាខ្ជិល ស្អីក៏ខ្ជិលដែរនឹង

គន្ធី ៖ អីគេខ្ជិលនឹង?

សុខន ៖ មនុស្សខូចនឹង ហើយខ្ញុំមិនខូចអីខ្ញុំ និយាយឲ្យត្រង់ គេឲ្យស៊ី២វែកខ្ញុំស៊ី២វែក ដេកទាល់ព្រឹកឡើងទៅធ្វើការ ដល់ពេលម៉ោងទៅធ្វើការទៀតៗ ហើយដល់ អឹង គាត់មិនជឿគេៗរាយ (ការណ៍)ម៉ាថ្ងៃៗ ដល់នេះគាត់មិនអស់ចិត្ត គាត់មកប្រាប់ អឹប៉ោះៗមេឃុំនឹង អឹប៉ោះទៅតាមដានខ្ញុំកន្លះខែ ខ្ញុំអត់ដឹងទេ គាត់នៅតែទៅៗ ដល់ខ្ញុំឡើងមកធ្វើការ គាត់ហៅខ្ញុំមកជិតគាត់ឲ្យថ្នាំម៉ាដើម ហើយដក់ម៉ាកញ្ចប់ អែង!យកថ្នាំម៉ាកញ្ចប់យកមកញ៉ុកៗ គាត់ឲ្យដក់នឹងយក គាត់សួរចេះសួរ ហើយយើងអត់ដឹងខ្លួន ខ្ញុំអត់ដឹងខ្លួនទេ គាត់ទៅតាមដាន បើខ្ញុំអីចឹងមែនអត់អាងគេវៃចោលៗ ហើយដល់ខ្ញុំមិនអីចឹង ខ្ញុំធ្វើការដឹង តែគេវាស់ឲ្យ២០ម៉ែត្រក្បាលហើយក៏១០ម៉ែត្រ ខ្ញុំដឹងតែខ្វាកៗហើយកាត់ស្មោនឹងៗ ដល់អីចឹងទៅ គាត់មិនជឿអឹងគេយកខ្ញុំទៅនៅជាមួយគាត់បានប្រហែលយូរដែរ ជាប់២០ថ្ងៃដែរបែបៗ គាត់យកមកដើរតាមគាត់នឹង អានឹងបានធូរចិត្តតិចហើយៗ គាត់យកមកនៅជាមួយគាត់នឹង បានស៊ីឆ្អែតមានពោះតិច លែងស្គមស្វិតក្បាលពោះៗ

គន្ធី ៖ ដូរក្រុមអីចឹងបានដែរ អឹង ប្រធានអឹងនឹង គាត់និយាយអាមួយប្រធាន អឹប៉ាល់ អីចឹង?

សុខន ៖ បាទ!

គន្ធី ៖ និយាយម៉េចទៅ បានអឹដូរមកបាន?

សុខន ៖ គាត់នេះ គេគាត់ថាដកយើងមក គាត់ស្រឡាញ់ គាត់មិនជឿគេទុកនៅនោះគេធ្វើបាប គេឲ្យស៊ីបាយមិនឆ្អែត គេស្អប់យើងៗ

គន្ធី ៖ គាត់ជឿ?

សុខន ៖ អានឹងចេះ អន្ទាល់និយាយហួស អន្ទាល់ពូប៉ាល់គាត់មិនទាន់មានគូស្រករ គេមិនទាន់ប្តេជ្ញាឲ្យកាលនឹងអាស៊ីមនឹងវានៅខ្វាច គាត់អត់ហ៊ានធ្វើបាបខ្ញុំទេៗ ដល់ប៉ាល់ គាត់ចេញរៀបប្តេជ្ញាឲ្យគេមកនៅតាមយុវជន តាមចាស់ៗ បានអានឹងគេឡើងដៃធ្វើបាបខ្ញុំម៉ង់ៗ

គន្ធី ៖ ស៊ីម ហើយស៊ីមនឹង គាត់ឡើងប្រធានវិញ?

សុខន ៖ ដល់គេឡើងប្រធានគេធ្វើបាបឃើញទេ គេធ្វើបាបងាប់ ។

គន្ធី ៖ ហើយរាល់ថ្ងៃគាត់នៅណាដែរ ស្លាប់?

សុខន ៖ ស៊ីម តាម៉ុលនឹង ។

គន្ធី ៖ ហើយដល់ពេលអ៊ំត្រូវដូរមក គេមាននៅតាមអ៊ំទៀតទេ?

សុខន ៖ អត់ទេ គេលែងតាមហើយ គេដឹងយើងមនុស្សស្លូត មនុស្សត្រង់ហើយ គេលែងតាមដាន យើង លែងធ្វើបាប ។

គន្ធី ៖ ចុះអ៊ំរបបម្ហូបអាហារអ៊ំពិសារម៉េចដែរ?

សុខន ៖ ដល់មកនៅជាមួយគេហូបមានអី ហូបគេហូបម៉េចយើងហូបអីចឹង គេឲ្យដាំបាយដាំដូចគ្នា ។

គន្ធី ៖ ដាំបាយដែរ?

សុខន ៖ បាយបបរដែរ តែបបរប៊ុក អាគេប្រធាននឹងហូបបបរប៊ុក អាយើងនេះបបរទឹករ៉ូវ(រាវ) គេ គ្រាន់ប្រធានបបរប៊ុករៀងគោកជាងយើង ហើយយើងប្រជាជនសុទ្ធយើងហូបទឹករ៉ូវ(រាវ) គេ ប្រធានប៉ក់ៗ(គោក) នេះទៅ ។

គន្ធី ៖ ចុះអ៊ំក្រោយមកធ្វើការអីចឹងទៅ មានដូចថាឃើញដូចថាអ៊ំដូរមកក្រុមផ្សេងទៀតអីចឹង មាន ប្រជាជនថ្មីធ្វើការជាមួយអ៊ំច្រើនទេ?

សុខន ៖ អានឹងអត់ទេ ខ្ញុំដល់កន្លែងនឹងបងអ៊ីងនឹងគាត់ហៅខ្ញុំដើរតាមគាត់ ដឹងតែស្ពាយ គាត់ឲ្យកាប៊ីនម៉ា ដើម ដឹងតែដើរតាមគាត់ ។

គន្ធី ៖ កាប៊ីន?

សុខន ៖ តែគាត់ឲ្យកាំភ្លើងម៉ាដើមកាំភ្លើងកាប៊ីនស្ពាយដើរតាមគាត់ ។ គាត់ដើរទៅណា គាត់ហៅទៅនឹង តាមគាត់២០ថ្ងៃដែរ ។

គន្ធី ៖ ដើរតាមគាត់រហូតមក?

សុខន ៖ បាទ!

គន្ធី ៖ តាំងពីនឹងមក?

សុខន ៖ ហើយដើរតាមគាត់២០ ដល់គេរើសទ័ពស្រុក គ្រាន់ថា«ឯងទៅទ័ពទេ» «មានអីបងឯងទៅ ណាខ្ញុំទៅនឹង» ដល់គាត់ឲ្យធ្វើទ័ព ខ្ញុំទៅទ័ពទៅទៀតទៅ ។

វិសាលៈ ឆ្នាំណាអ៊ំ?

សុខន ៖ អារឿងឆ្នាំនឹងមិនចេះចាំទេ ។

វិសាលៈ ពេលអ៊ំមកវិញធ្វើការកងចល័តប្រហែលបានប៉ុន្មានឆ្នាំ បានតាមិញគេឲ្យអ៊ំធ្វើកងទ័ពស្រុក?

សុខន ៖ មកបានប្រហែលម៉ាឆ្នាំ ។

វិសាលៈ ម៉ាឆ្នាំ៧៦ ចូល៧៦?

សុខន ៖ បាទ! ប្រហែលម៉ាឆ្នាំ ។

វិសាលៈ អាចថាពាក់កណ្តាល៧៦?

សុខន ៖ បាទ!

វិសាលៈ លោកតាឈ្មោះអីគេ?

សុខន ៖ អឺ! រឿងអីចឹងៗកាលលើកមុនគ្មានអ្នកណាគិតខែ គិតថ្ងៃអីទេ ដឹងតែភ្លឺឡើងធ្វើម៉ង ។

គន្ធី ៖ គាត់ដើរជាមួយនឹង?

វិសាលៈ បាទៗ

គន្ធី ៖ តាអ៊ីង ។

វិសាលៈ តាអ៊ីង នឹង បន្ទាប់ពីអ៊ំមកនៅក្នុងភូមិ បន្ទាប់ពីបែកបានម៉ាឆ្នាំ នៅប្រហែលបានម៉ាឆ្នាំ តាអ៊ីង នឹងគាត់ស្រឡាញ់អ៊ំ គាត់ពេញចិត្តអ៊ំ គាត់ហៅអ៊ំចូលធ្វើទាហានស្រុកទៅ?

សុខន ៖ បាទ!

វិសាលៈ ហើយអ៊ំថាម៉េចទៅ?

សុខន ៖ ខ្ញុំមានថាម៉េច បងឯងឲ្យខ្ញុំទៅណា ខ្ញុំទៅនឹង ដល់ទៅទ័ពស្រុកទៅនៅជាមួយតាណាំ ។

គន្ធី ៖ ទៅនៅជាមួយតាណាំ ដូរប្រធានទៀត?

សុខន ៖ បាទ! ដូរប្រធានទៅនៅជាមួយតាណាំ ។

គន្ធី ៖ ចុះតាអ៊ីងម៉េចវិញទៅ?

សុខន ៖ តាអ៊ីងគេនៅនឹងដដែល នៅឃុំវជនឃុំកំពែង ។

គន្ធី ៖ ចុះអ៊ំកាន់កាប៊ីនគេនឹង ដើរទៅណាខ្លះដែរ?

សុខន ៖ ដើរតែនៅក្នុងឃុំកំពែងនឹង ចុះតាមភូមិទៅតាមភូមិនឹងគេ ។

គន្ធី ៖ ធ្វើអីដែរ ដើរតាមភូមិ?

សុខន ៖ ដើរមើលតែគេ គេមានធ្វើអីគេឃុំ ។

គន្ធី ៖ មើលម៉េចទៅ?

សុខន ៖ មើលប្រជាជនធ្វើការ ជីកព្រែកជីកប្រឡាយអញ្ចឹងណា៎ ។

វិសាលៈ ដូចយើងធ្វើអន្តរក្សគេអញ្ចឹងណា៎

សុខន ៖ ដូចយើងធ្វើនារសាគេណា៎ ។

គន្ធី ៖ ធ្វើនារសាដែរអ៊ំ?

សុខន ៖ បាទ!

គន្ធី ៖ ហើយអ៊ំមានដែលយករបស់ពីណាទៅណា ដូចថាគេធ្វើរដូចថានារសារអញ្ចឹងណា៎?

សុខន ៖ គេអត់ដែលធ្វើរទេ អានេះដូចថាខ្ញុំផ្ទាល់ជាមួយគាត់ គាត់ទៅណាខ្ញុំទៅហ្នឹង ហើយយប់ឡើង ពេលគាត់ដេកអញ្ចឹងយើងយាម ហើយបើងងុយយើងដេកដែរទៅ យើងនារសាគេអញ្ចឹង ហើយ ។

គន្ធី ៖ អញ្ចឹងគាត់អត់ដែលធ្វើរបស់ដូចថាទៅណា ហើយអ៊ំធ្វើនារសាជាមួយគាត់បាន២០ថ្ងៃមែន ទេ?

សុខន ៖ អត់មានដែលធ្វើអីទេ កាលនៅហ្នឹងស្រួលចិត្តណាស់ មិនសូវពិបាកទេ បាយក៏បានស៊ីឆ្អែត ហើយខ្ញុំនិយាយត្រង់ ខ្ញុំកុំតែបានមិត្តភ័ក្រ្តស្រលាញ់ បានអា ម៉ៅ ប្តីមី ខន នេះឲ្យតែយប់ ឡើងបើមិនដូងទេ បាយពួកប៉ុនៗនេះយកមកហុចឲ្យហើយ ព្រោះវាស្រលាញ់គ្នា ចុះបាយគេឲ្យ តែពីរបីក្រឡុកប៉ុណ្ណេះទេ អាម៉ៅ គេដើរដឹកខសដាក់តាមកង ហើយអា ឈឿន គេដឹកខសដែរ ហើយអាមួយយកដូងអាមួយទៀតយកបាយអញ្ចឹងម៉ោ ហើយ អាម៉ៅ គេថាគេរកត្រី ហើយ អាឈឿន គេដឹកខស កុំតែបានពួកអស់ហ្នឹងវាលួចឲ្យស៊ីយប់ ហ្នឹងកុំអីមិនដឹងម៉េចទេ ។

គន្ធី ៖ សុទ្ធតែលួចឲ្យទៀត?

សុខន ៖ បាទ! សុទ្ធតែលួច ។

គន្ធី ៖ ម៉េចអញ្ចឹងអ៊ំ?

សុខន ៖ ទោះបីជាខ្ញុំបានដំឡូងប៉ុណ្ណេះហើយឲ្យក្មួយឯង ទាល់តែលួចលាក់ ដើរជិតគ្នាមិនហ៊ានហៅផង ដូចថាហុចឲ្យអញ្ចឹងក្មួយឯងដឹងចាប់ដៃយកទៅបេះហូបមួយម៉ាត់ហើយដាក់កំប៉ោវិញទៅ ព្រោះ ខ្លាចគេឃើញ បើយើងមានហូបលើសគេហ្នឹង គេហៅយើងទៅកសាងហើយ យើងខ្លាច ប្រធានគេ ។

គន្ធី ៖ ប្រធានយ៉ាងម៉េចទៅ ឲ្យតែគេឃើញគេចាប់យើងទៅកសាងមែន?

សុខន ៖ បាទ!

គន្ធី ៖ ប្រធានហ្នឹងយ៉ាងម៉េចទៅ ដូចថាគាត់ជាប្រធានរបៀបម៉េចបានធ្វើឲ្យយើងខ្លាច?

សុខន ៖ គេប្រធានកងយើងហ្នឹង ប្រធានគេកសាងយើង ហើយគេសួរយើងថាយើងបានពីណាយកមក ហូបអញ្ចឹងណា៎ ។

គន្ធី ៖ ធ្លាប់មានអ្នកចាប់បានអញ្ចឹងដែរ?

សុខន ៖ មាន ។

គន្ធី ៖ អ្នកណាគេចាប់បានដែរអ៊ំ?

សុខន ៖ ខ្វះអី ។

គន្ធី ៖ ប្រជាជនខាងណាវិញ?

សុខន ៖ សុទ្ធតែគ្នាឯងនៅក្នុងកងហ្នឹង ប្រធានគេចាប់ហើយឲ្យតែយើងមានអីស៊ី ។

គន្ធី ៖ អ្នកណាគេខ្វះអ៊ំមានស្គាល់ទេ អ្នកដែលត្រូវគេចាប់បានហ្នឹង?

សុខន ៖ សុទ្ធតែគ្នាឯងក្នុងស្រុកហ្នឹង ឲ្យតែយើងមានអីស៊ីហួសគេ គេចាប់ហើយព្រោះគេថាយើងលួចពីណាមក ដូចថាដំឡូងបើគេចែកមួយកន់គឺមួយកន់ហើយ បើហួសពីហ្នឹងក៏យើងមិនដឹងបានពីណា ដែរ ។

គន្ធី ៖ ហើយធ្លាប់មានអ្នកណាគេខ្វះដែលចាប់បាន?

សុខន ៖ មិនចាំទេក្មួយ ។

គន្ធី ៖ ប្រជាជនក្នុងស្រុកហ្នឹងអ៊ំមានចាំខ្វះទេ ដែលអ៊ំថាសុទ្ធតែគ្នាឯងអញ្ចឹងណា៎ ឈ្មោះអីខ្វះដែរអ៊ំ?

សុខន ៖ អារឿងពួកខ្ញុំយុវជនហ្នឹងវាមិនសូវអីទេគេចាប់ហ្នឹង យកទៅកសាងនាយអាយទៅគេឲ្យទៅធ្វើការវិញ ។

គន្ធី ៖ ហើយអ៊ំថាគេកសាងផ្សេងទៀត ហើយថាខ្លាចគេយកទៅសម្លាប់ ម៉េញអ៊ំមានប្រសាសន៍អញ្ចឹង?

សុខន ៖ បាទ!

គន្ធី ៖ ធ្លាប់មានគេយកទៅសម្លាប់ដែរអ៊ំ?

សុខន ៖ គេយកតើ ឲ្យតែយើងធ្វើខុស ។

គន្ធី ៖ ហើយគេយកអ្នកណាខុសម៉េចទៅ ជាប្រជាជនយ៉ាងម៉េចដែរបានគេយកទៅសម្លាប់?

សុខន ៖ យើងកំពុងធ្វើការអញ្ចឹង គ្រាន់តែយើងនិយាយខុសបន្តិចហ្នឹងគេថាយើងខ្មាំង ហើយគេយកយើងទៅវ៉ៃចោលហើយ ។

គន្ធី ៖ និយាយម៉េចទៅខុស?

សុខន ៖ យើងនិយាយមិនដឹងគេស្តាប់យើងថាម៉េច ។

គន្ធី ៖ ច្រើននាក់ទេអ៊ំ អ្នកដែលគេយកទៅកសាងអញ្ចឹង?

សុខន ៖ មិនខុះទេក្មួយ គេវៃក្បែរៗព្រៃរំពាក់ហ្នឹង ឲ្យតែយប់ឡើងគេយកទៅបាត់ហើយ អត់មានដឹងអីទេ ដឹងតែដេកញាក់ទៅ ។

គន្ធី ៖ ចុះម៉េចអ៊ំដឹងថាគេយកទៅសម្លាប់?

សុខន ៖ ចុះបើយកទៅបាត់ៗ អត់មានឃើញមកធ្វើការវិញ ។

គន្ធី ៖ អ៊ំឃើញគេយកទៅមែន?

សុខន ៖ ឲ្យតែថ្ងៃល្ងាចឡើងគេយកទៅហើយ ផងឹតៗហ្នឹងគេហៅចុះទៅហើយ ហើយពេលដែលចុះទៅយើងដែលនៅហ្នឹងដឹងតែរួញជើងហើយ ។

គន្ធី ៖ ហើយហៅចុះទៅហ្នឹង អ៊ំមានដឹងថាអ្នកហ្នឹងខុសអីទេ?

សុខន ៖ យើងមិនដឹងថាខុសទេ គឺស្រេចតែគេទេ ។

គន្ធី ៖ អ៊ំឃើញផ្ទាល់ភ្នែកទេ?

សុខន ៖ ចុះបើនៅដេកជាមួយគ្នាឃើញហើយ អាហ្នឹងផ្ទាល់ភ្នែកហើយ គេហៅទៅយើងទៅក្រុះហើយ ទៅបាត់ទៅ ។

គន្ធី ៖ កាលហ្នឹងឈ្មោះអីគេដែរ ដែលដេកជាមួយអ៊ំហ្នឹង?

សុខន ៖ អាពួកអ្នកថ្មី អាសេរីក្រោយយើងមានដឹងទេ ហើយក៏មិនដឹងថាគេវៃនៅណាដែរ ដឹងតែគេនាំទៅបាត់ឈឹង ។

គន្ធី ៖ អ្នកហ្នឹងធ្វើអីដែរបានជាគេហៅទៅ?

សុខន ៖ ខ្ញុំមិនដឹងដែរក្មួយ ។

គន្ធី ៖ ហើយប៉ុន្មាននាក់ដែរ ដែលគេហៅយកទៅហ្នឹង?

សុខន ៖ ២នាក់ ។

គន្ធី ៖ កាលហ្នឹងពេលណាដែរអ៊ំ?

សុខន ៖ កាលហ្នឹងនៅយុវជន ។

គន្ធី ៖ ពេលថ្ងៃឬក៏ពេលយប់?

សុខន ៖ ពេលយប់ ។

គន្ធី ៖ ប្រហែលជាម៉ោងប៉ុន្មានដែរអ៊ំ?

សុខន ៖ ម៉ោង៧-៨ហ្នឹង យើងដេកលក់មួយស្របក់ហ្នឹង ។

គន្ធី ៖ គេហៅថាម៉េចទៅ អ៊ំមានឮទេ?

សុខន ៖ គេហៅហ្នឹងគេថារកជូនទៅនេះទៅនោះអញ្ចឹងណា៎ គេប្រើល្បិចណា៎ ។

គន្ធី ៖ ហើយអ្នកហៅហ្នឹងមានគ្នាប៉ុន្មាននាក់ដែរអ៊ំ?

សុខន ៖ អ្នកហៅមានតែប្រធានឈ្លបគេ២-៣នាក់ហ្នឹង ។

គន្ធី ៖ ប្រធានអីដែរអ៊ំ ឈ្មោះអីដែរ?

សុខន ៖ ឧទាហរណ៍ថាដូច ប្រធានកងគេអញ្ចឹងណា៎ ។

គន្ធី ៖ ឈ្មោះអីដែរអ៊ំ?

សុខន ៖ ឧទាហរណ៍ថាដូច អាស៊ុម អញ្ចឹងវាប្រធានវាដឹងហើយថាអានេះអញ្ចេះអានោះអញ្ចេះ ដល់ហើយគេចុចមកហៅយកទៅ ។

គន្ធី ៖ អ៊ំមានស្គាល់អ្នកដែលហៅយកទៅហ្នឹងទេ ដូចជាប្រធានកងឈ្លប អ៊ំមានស្គាល់ទេ ។

សុខន ៖ ពួកហ្នឹងងាប់អស់ហើយ ។

គន្ធី ៖ អ្នកងាប់អស់ហ្នឹងឈ្មោះអីគេដែរ អ៊ំមាននៅចាំទេ?

សុខន ៖ ឈ្មោះ សេរី តែមិនមែននៅស្រុកយើងទេ នៅស្រុកណាណីណោះ គ្រាន់ថានៅយុវជនជាមួយគ្នាហ្នឹង សុទ្ធតែពួកថ្មី ។

គន្ធី ៖ ហើយគេហៅអញ្ចឹងញឹកញាប់ទេ ម៉េញអ៊ំមានប្រសាសន៍ថាមិនខ្វះមនុស្សទេ អញ្ចឹងមានន័យមានមនុស្សច្រើននាក់ហើយមែនទេ?

សុខន ៖ អាហ្នឹងតែយើងធ្វើខុសយូៗគេហៅហើយ ។

គន្ធី ៖ អ៊ំអាសាឃើញទេ?

សុខន ៖ បានឃើញតែ២នាក់ហ្នឹងទេ ព្រោះនៅដេកជាប់គ្នា ។

គន្ធី ៖ ចុះអ៊ំថាមិនខ្វះមនុស្សច្រើននាក់អញ្ចឹង?

សុខន ៖ អាច្រើននាក់ហ្នឹង អាខ្លះគេហៅយកទៅកសាងហើយគេឲ្យយកមកវិញអញ្ចឹងណា៎ អាហ្នឹងការមិនពិត បើអ្នកណាពិតគេយកទៅសម្លាប់ចោល ។

គន្ធី ៖ ហើយអ៊ំម៉េចដឹងថាកសាងពិតឬមិនពិត?

សុខន ៖ ចុះតែឃើញមកវិញគឺមិនពិតហើយ តែអាពិតបាត់ឈឹង ។

គន្ធី ៖ ហើយធ្វើម៉េចបានដឹងពិតទៅអ៊ំ?

សុខន ៖ ខ្ញុំមិនដឹងដែរ គេមិនឲ្យយើងទៅស្តាប់គេទេ មិនហ៊ានកម្រើកខ្លួនផង ។

គន្ធី ៖ ចុះអ៊ំធ្លាប់មានអ្នកខុសសិលធម៌ក្នុងភូមិអ៊ំទេ ។

សុខន ៖ ក្នុងភូមិមិនដឹងទេ ។

គន្ធី ៖ ក្រែងកាលហ្នឹងអ៊ំធ្វើការនៅក្នុងភូមិហ្នឹងដែរ?

សុខន ៖ ធ្វើការក្នុងភូមិតែធ្វើជាមួយចាស់ៗ តែចាស់ៗមិនដែលខុសអីទេ ។

គន្ធី ៖ អញ្ចឹងនៅក្នុងភូមិដែលអ៊ំនៅហ្នឹងមានដែលខុសសីលធម៌ដែរ?

សុខន ៖ អត់ ។

គន្ធី ៖ ហើយមានដែលដូចថា ផ្ដើលរឿងដូចថា ឃើញមនុស្សស្លាប់នេះស្លាប់នោះ មានដែលទេ?

សុខន ៖ អត់ដែលទេ ។

គន្ធី ៖ អត់ដែលផ្ដើលទេ?

សុខន ៖ បាទ!

គន្ធី ៖ ចុះអ៊ំដល់ពេលនៅក្នុងភូមិអ៊ំអញ្ចឹង ដូចថាក្រោយម៉ោពេលដែលអ៊ំចប់ពីការដើរតាមមេកង អង ហ្នឹងទៅណាទៀតមេកង អង ហ្នឹង?

សុខន ៖ ទៅទ័ពស្រុក ។

គន្ធី ៖ ទ័ពស្រុកហ្នឹងមានប៉ុន្មាននាក់ដែរ ដែលអ៊ំចូលធ្វើ?

សុខន ៖ ច្រើនណាស់ កាលហ្នឹងមានរាប់រយនោះ ។

គន្ធី ៖ មកពីខាងណាវិញអ្នកដែលចូលរួមហ្នឹង ។

សុខន ៖ ពីណាៗមិនដែលខ្វល់គេទេ ។

គន្ធី ៖ ហើយម៉េចបានជាអ៊ំទៅធ្វើទ័ពស្រុកវិញ?

សុខន ៖ គេបញ្ជូនយើងឲ្យទៅយើងចេះតែទៅ ទៅតាមគេ ។

គន្ធី ៖ អ្នកណាអ្នកបញ្ជូនអ៊ំទៅ?

សុខន ៖ គេសួរអញ្ចឹងហើយយើងស្ម័គ្រចិត្តយើងទៅណា៎ ។

គន្ធី ៖ អញ្ចឹងអ៊ំស្ម័គ្រចិត្តទៅទេ?

សុខន ៖ បាទ!

គន្ធី ៖ គេហ្នឹងពីណាគេ?

សុខន ៖ អង ហ្នឹង ។

គន្ធី ៖ គាត់សួរថាម៉េចដែរអ៊ំ?

សុខន ៖ គាត់សួរថាឯងទៅទ័ពស្រុកទេ ដល់ហើយខ្ញុំថាបើបងឯងឲ្យទៅខ្ញុំទៅ បើបងឯងឲ្យនៅខ្ញុំនៅ ដល់ហើយគាត់អញ្ចឹងឯងទៅ ។

គន្ធី ៖ គាត់មានប្រាប់ថាទៅទ័ពស្រុកហ្នឹងទៅធ្វើអីទេអ៊ំ?

សុខន ៖ ទៅទ័ពស្រុកហ្នឹងទៅត្រៀមរវៃជាមួយយួនអញ្ចឹងណា៎ ។

គន្ធី ៖ កាលហ្នឹងរាប់រយនាក់ហ្នឹងមានអ្នកណាគេខ្លះអ៊ំ មាននៅចាំខ្លះទេ?

សុខន ៖ ចាំមិនអស់ទេ ព្រោះមនុស្សច្រើនណាស់ ដឹងតែ តាណាំ ហ្នឹងគាត់ប្រធាន ។

គន្ធី ៖ តាណាំ ហ្នឹងគាត់ប្រធានអីគេដែរអ៊ំ?

សុខន ៖ គាត់ប្រធានទ័ពហ្នឹង កងស្រុកហ្នឹង ។

គន្ធី ៖ កងហ្នឹងមានឈ្មោះអីដែរអ៊ំ មាននៅចាំទេ?

សុខន ៖ គេហៅកងស្រុកហ្នឹង ។

គន្ធី ៖ មានលេខគេដែរអ៊ំ?

សុខន ៖ អត់មានទេ ។

គន្ធី ៖ ដូចថាមានលេខកងប៉ុន្មានប្រចាំតំបន់គេ ហើយស្រុកប៉ុន្មានអញ្ចឹង?

សុខន ៖ អត់មានទេ គេហៅតែកងៗ ដល់ពេលខ្ញុំចេញពីកងស្រុកហ្នឹងទៅទ័ព កងពល៤១០ ។

គន្ធី ៖ ហើយវរៈសេនាប៉ុន្មានទៅ?

សុខន ៖ មិនដឹងប៉ុន្មានទេកាលហ្នឹង ។

គន្ធី ៖ ហើយពេលទៅហ្នឹងគេរឹកហាត់បណ្តុះបណ្តាលអ៊ំយ៉ាងម៉េចដែរ?

សុខន ៖ កន្លែងហាត់កន្លែងរឹក ដល់ពេលទៅគេឲ្យទៅនៅត្រៀមក្បែស្រុកយួននោះ ។

គន្ធី ៖ ហើយចុះអ៊ំមានធ្លាប់កាន់កាំភ្លើងពីមុនមកទេ?

សុខន ៖ អត់ដែលសោះ ។

គន្ធី ៖ អញ្ចឹងធ្វើយ៉ាងម៉េចទៅអ៊ំ?

សុខន ៖ មុនដំបូងញាក់ ដល់ពេលបានយួនបុកមកហើយបាញ់មួយគ្រាប់មកលែងញាក់ហើយ ។

គន្ធី ៖ យ៉ាងម៉េចវិញអ៊ំ ដូចថាពេលអ៊ំទៅគេមានបង្ហាត់អ៊ំទេ?

សុខន ៖ ហាត់តាំងពីពេលនៅកងស្រុកនោះ ហាត់បាញ់ស៊ីភ្លេងនាយអាយហ្នឹងណ៎ា ។

គន្ធី ៖ ហាត់បានរយៈពេលប៉ុន្មានដែរអ៊ំ?

សុខន ៖ ហាត់បានរយៈពេល២អាទិត្យ ។

គន្ធី ៖ ដូចថាគេមានប្រាប់យើងយ៉ាងម៉េចខ្លះ?

សុខន ៖ គេប្រាប់ឲ្យយើងរបៀបលូន របៀបក្រាបហ្នឹង ហើយប្រាប់ឲ្យបាញ់អញ្ចេះបាញ់អញ្ចោះ ។

គន្ធី ៖ ដល់ក្រោយពី២អាទិត្យហ្នឹងអ៊ំទៅធ្វើអីទៀត?

សុខន ៖ ហើយគេបញ្ជូនទៅទៀត ។

គន្ធី ៖ ទៅដល់ណាទៅអ៊ំ?

សុខន ៖ នៅជាប្តីនៅហ្នឹង ទៅនៅកងទ័ព ។

គន្ធី ៖ ហើយកាលហ្នឹងសមាជិកអីប៉ុន្មាននាក់ដែរ គ្នារបស់អ៊ំ?

សុខន ៖ គ្នាច្រើនណាស់ តែបែកគ្នាអស់ហើយ ។

គន្ធី ៖ ប៉ុន្មាននាក់ដែរអ៊ំ គ្នាអីដែលធ្វើការហ្នឹង?

សុខន ៖ មួយក្រុមហ្នឹងគ្នា៣០នាក់ ។

គន្ធី ៖ ពីណាគេប្រធានអ៊ំ?

សុខន ៖ ប្រធានអាប៊ុ វ៉ុន នៅស្រុក១០៥ ។

គន្ធី ៖ គាត់មកពីខាងណាវិញ?

សុខន ៖ សុទ្ធតែមកពី១០៥ គេមកត្រួតយើងនៅហ្នឹង ។

គន្ធី ៖ ដល់ហើយយ៉ាងម៉េចទៀត ដល់ពេលចាប់ផ្តើមប្រតិបត្តិការណ៍យើងហាត់បាន២អាទិត្យ?

សុខន ៖ ទៅបាញ់ហ្នឹងអាណាងាប់ៗ អាណាមិនចេះបាញ់ មិនចេះក្រាប មិនចេះលូន ហើយខ្ញុំតែបាញ់ មិនត្រូវមិតមកក្រោយវិញហើយ ។

គន្ធី ៖ ហើយអ៊ំឧបមាថាគ្នាអ៊ំកំពុងតែបាញ់អញ្ចឹងទៅ មានអ្នកគេត្រូវរបួសស្លាប់អីដែរ?

សុខន ៖ ពេលត្រូវរបួសយើងយកគេមក ហើយស្លាប់ក៏យើងយកគេមកដែរ ។

គន្ធី ៖ ច្រើននាក់ទេអ៊ំ ក្រុមរបស់អ៊ំដែលត្រូវរបួស?

សុខន ៖ មួយសាខាយើងមាន៣នាក់ មួយគ្រង់សេ ។

គន្ធី ៖ ៣នាក់?

សុខន ៖ បាទ!

គន្ធី ៖ ហើយប្រចាំការធ្វើយ៉ាងម៉េចខ្លះទៅអ៊ំ?

សុខន ៖ ដូចយើងយាមទាំងយប់យាមទាំងថ្ងៃហ្នឹង ។

គន្ធី ៖ ហើយបាញ់គ្នាយ៉ាងម៉េចទៅអ៊ំ ដូចថាពេលណាបាញ់ពេលយប់ពេលថ្ងៃអញ្ចឹងអ៊ំ ប្រចាំការធ្វើយ៉ាងម៉េចខ្លះទៅអ៊ំ?

សុខន ៖ ពេលយួនមកពេលថ្ងៃយើងបាញ់ថ្ងៃ ពេលយួនមកពេលយប់យើងបាញ់យប់អញ្ចឹងណា៎ តែពេលថ្ងៃយើងអត់មានឃើញមនុស្សទេ ឃើញតែគ្រាប់ចៀកកាំភ្លើងទេ ហើយមនុស្សនៅតែក្នុងដី ទេ គេជីកត្រង់សេ ។

គន្ធី ៖ ហើយចុះពេលហូបចុកធ្វើម៉េចទៅ ពេលឃ្លានបាយហើយយើងកំពុងតែបាញ់គ្នាអញ្ចឹង ។

សុខន ៖ អត់សិនទេ ដល់ពេលយប់បានហូប

បើមិនអញ្ចឹងទេពេលស្វាត់កាំភ្លើងយើងហូបក្នុងត្រង់សេទៅ គ្នាយើង៣នាក់ហ្នឹង ។

គន្ធី ៖ ហើយ៣នាក់ហ្នឹងពេលបាញ់គ្នាដូចថាអត់អីដូចអីដែរ?

សុខន ៖ មានអី ឧទាហរណ៍ថាត្រូវមួយអញ្ចឹង ពេលយប់ឡើងឈប់បាញ់ហ្នឹងយើងយកវាចេញទៅយកមកក្រោយមក ។

គន្ធី ៖ ចុះអ៊ំធ្វើម៉េចទៅ ធម្មតាប្រាកដជាអ៊ំប៊ិនប្រសព្វរឿងអីមួយហើយមួយជីវិតមកអញ្ចឹង ហើយម៉េចខ្លះទៅអ៊ំរឿងវិធីបាញ់ ហើយគេចខ្លួនម៉េចទៅ?

សុខន ៖ គ្រាន់ថាពូកែគេចពូកែក្រាប ពូកែជីកត្រង់សេ បើអ្នកណាខ្ជិលជីកត្រង់សេហ្នឹងអើយ ។

គន្ធី ៖ អ៊ំជីកត្រង់សេដែរ?

សុខន ៖ ជីកត្រង់សេ ធ្វើគម្រប ត្រង់សេត្រឹមចង្កេះ ហើយធ្វើគម្រប ហើយយប់ឡើងតែផ្លាស់មួយទៅកន្លែងមួយហ្នឹងជីកតែត្រង់សេហើយដាំស្មៅជិតឈឹង ។

គន្ធី ៖ ហើយបាញ់គ្នាជាមួយវៀតណាមហ្នឹងរយៈពេលប៉ុន្មានដែរអ៊ំ?

សុខន ៖ មិនដឹងប៉ុន្មានទេ តែមួយប្រាវៗហ្នឹងពេលវាមក ។

គន្ធី ៖ រយៈពេលប៉ុន្មានដែរពេលបាញ់ជាមួយគ្នាហ្នឹង?

សុខន ៖ ជួនកាលកន្លះម៉ោង ជួនកាលមួយម៉ោង ។

គន្ធី ៖ ហើយចុះពេលណាអ៊ំបាញ់បញ្ចប់ជាមួយវៀតណាម ប្រហែលជាពេលណាដែរ ដូចថាប៉ុន្មានខែប៉ុន្មាននេះដែរ?

សុខន ៖ ខ្ញុំបាញ់នៅនេះបានតែមួយដងទេ ហើយគេបញ្ជូនខ្ញុំទៅបូព៌ា ។

គន្ធី ៖ អញ្ចឹងអត់ទាន់វៃចប់ផង គេបញ្ជូនអ៊ំទៅបូព៌ា?

សុខន ៖ នៅ ដល់ហើយគេបញ្ជូនទៅបូព៌ា ។

គន្ធី ៖ ដល់ពេលវៃអញ្ចឹងទៅម៉េចដែរអ៊ំ ដូចថាមានខាងគេខាងយើងចាប់គ្នាទៅវិញទៅមក ដែលគេហៅថាជាឈ្លើយសឹកអញ្ចឹង មានទេអ៊ំ?

សុខន ៖ មានគេចាប់តើ អាណាគេហ៊ានគេមិតទៅចាប់ទៅ បើយើងបាក់វា វាចាប់យើង តែបើវាបាក់យើង យើងចាប់វាទៅ ។

គន្ធី ៖ ហើយចុះក្រុមអ៊ំមានដែលចាប់បានទេ?

សុខន ៖ ខ្ញុំស៊ុំគេទៅនៅតែចុងៗទេ ព្រោះស្រណុករត់ ។

វិសាលៈ ចុងហ្នឹងបានន័យថានៅខាងក្រោយគេហ្នឹង?

សុខន ៖ អត់ទេ នៅខាងគេបង្អស់

វិសាលៈ អ៎! នៅខាងគេហ្នឹងកន្លែងដែលមានសុវត្ថិភាពហ្នឹង?

គន្ធី ៖ បាទ! នៅខាងគេបង្អស់ ចាំមើលម៉េចៗស្រណុករត់ហើយ ។

វិសាលៈ អ៊ំសុំសួរបញ្ជាក់បន្តិច មុនហ្នឹងអ៊ំមានប្រសាសន៍ថា តាអង ហ្នឹងគឺប្រហែលជាស្មើរឲ្យអ៊ំធ្វើទ័ព ហ្នឹងប្រហែលជាពាក់កណ្ដាល៧៦ ព្រោះអ៊ំនៅបានមួយឆ្នាំ តាអង ឲ្យធ្វើទ័ព ហើយធ្វើទ័ពទាហានស្រុកហ្នឹងបានរយៈពេលប៉ុន្មានបានអ៊ំចេញទៅកង៤១០ហ្នឹង?

សុខន ៖ នៅកងស្រុកហ្នឹងប្រហែលជា២ខែហ្នឹង ។

វិសាលៈ ហើយចុង៧៦បានទៅកងពល៤១០?

សុខនៈ ហើយគេចែកជាកងវរៈសេនាតូចទៀត ។

វិសាលៈ ដល់ពេលទៅព្រំប្រទល់វៀតណាម ថាបាញ់គ្នាម្ដងហ្នឹងអ៊ំមានដឹងថាតំបន់ហ្នឹងឈ្មោះអីទេ?

សុខនៈ នៅហ្នឹងគេហៅកន្លែងដើមដូង ។

វិសាលៈ ហើយបានហាត់២អាទិត្យ ហើយបាញ់គ្នាតែម្ដង?

សុខន ៖ បាទ!

វិសាលៈ អញ្ចឹងវៀតណាមហើយខ្មែរបាញ់គ្នាតាំងពី៧៦ម្លេះ បើតាមអ៊ំមានប្រសាសន៍?

សុខន ៖ បាទ!

វិសាលៈ កាលហ្នឹងអត់ទាន់មានចូលដីគេទេ គ្រាន់តែប្រាវៗតាមព្រំដែនទេ?

សុខនៈ កាលហ្នឹងយើងគ្រាន់តែត្រៀមព្រំដែនទេ ។

វិសាលៈ អត់ទាន់ចូលដល់ទឹកដីគេទេ?

សុខនៈ បាទ!

គន្ធី ៖ ចុះអ៊ំមានមួយរឿងៗណាទេ ដែលថាយើងពិបាកទប់ទល់ ដូចថាពេលបាញ់គ្នាអញ្ចឹង?

សុខន ៖ ពិបាកដែរ ពេលដែលបុកខ្លាំងទាល់តែយើងដកមិត បើយើងទប់មិនជាប់យើងមិតហើយ ។

គន្ធី ៖ ពេលបាញ់គ្នាហ្នឹងគេរត់ចូលមកនូវ ដូចថាវៀតណាមសម្រុកចូលមកនូវមុនពេលអ៊ំទៅបូព៌ហ្នឹង?

សុខន ៖ អាហ្នឹងនូវទេ មិនទាន់សម្រុកចូលមកទេ ។

គន្ធី ៖ ហើយម៉េចបានជាគេដកអ៊ំទៅបូព៌វិញ?

សុខន ៖ ព្រោះនៅភូមិនោះវាមាំជាងនៅនេះ ។

គន្ធី ៖ មាំយ៉ាងម៉េចទៅអ៊ំ?

សុខន ៖ គេខ្លាំងជាងនេះ គេវ៉ៃខ្លាំងជាងនេះ យើងនេះមិនសូវវ៉ៃខ្លាំងទេ ពេលយួនបុកមកអញ្ចឹងគេដក យើងទៅ ។

គន្ធី ៖ អ្នកណាគេអ្នកដកអ៊ំយកទៅ?

សុខន ៖ ខ្ញុំមិនដឹងដែរ ប្រធានកងពលគេហៅទេ គេយកតាមប្រធានកងវរយទៅ ។

គន្ធី ៖ កាលហ្នឹងទៅគ្នាច្រើនទេ ប្រហែលជាប៉ុន្មាននាក់ដែរ?

សុខន ៖ ទៅគ្នា៩ឡាន ។

គន្ធី ៖ ៩ឡានហ្នឹងប្រហែលជាប៉ុន្មាននាក់ដែរអ៊ំ?

សុខន ៖ ច្រើនណាស់៩ឡាន ។

គន្ធី ៖ សុទ្ធតែកងពលទាហានទាំងអស់?

សុខន ៖ បាទ!

គន្ធី ៖ អ្នកចូលធ្វើទាហានហ្នឹង ប្រជាជននៅក្នុងភូមិអ៊ំភាគច្រើនឬមួយក៏មកពីខាងណាដែរដែលធ្វើទាហាន ដូចថាមកពីក្រុមខេត្តផ្សេងអញ្ចឹង?

សុខន ៖ អាភូមិខ្លួនឯងហ្នឹងមិនដែលជួបគ្នាទេ សុទ្ធតែស្រុក១០៥ ស្រុកគេទាំងអស់ ពីណាមកនៅរួមគ្នាហ្នឹង ចេះតែស្គាល់គ្នាអញ្ចឹងទៅណា៎ អារឿងស្រុកភូមិឯងមិនដែលជួបទេ ។

គន្ធី ៖ ម៉េញអ៊ំថាប្រធានកងដែលដកអ៊ំហ្នឹងឈ្មោះអីដែរអ៊ំ អ្នកដែលដកអ៊ំយកទៅបូព៌ាវិញ?

សុខន ៖ អាហ្នឹងប្រធានកងវរយខ្ញុំគេដកឲ្យទៅហ្នឹង ។

គន្ធី ៖ ឈ្មោះអីដែរអ៊ំប្រធានកងវរយម៉េញហ្នឹង?

សុខន ៖ ឈ្មោះ រ៉ុន ។

វិសាលៈ គាត់នៅណាដែរ?

សុខនៈ នៅស្រុក១០៥ ។

វិសាលៈ សព្វថ្ងៃគាត់នៅរស់ទេ?

សុខនៈ មិនដឹងម៉េចទេ ព្រោះបែកគ្នាអាគាត់អាគាយ ។

គន្ធី ៖ គេប្រាប់អ៊ំថាយ៉ាងម៉េចខ្លះបានគេឲ្យអ៊ំទៅបូព៌ាហ្នឹង?

សុខន ៖ គេហៅទៅបូព៌ាអញ្ចឹង គេហៅទៅ មួយកងគេដកគ៣-៤នាក់អញ្ចឹងទៅ មកភូមិភាគបាន៩ឡានបានទៅ ។

គន្ធី ៖ មួយឡានប្រហែលជាប៉ុន្មាននាក់ទៅអ៊ំ?

សុខន ៖ មួយឡានជិះប្រហែលជា៨-៩នាក់ហ្នឹង គេអត់ឲ្យជិះច្រើនទេ ។

វិសាលៈ ឈរដេីងនៅព្រំដែនបានប៉ុន្មានខែបានគេដកទៅអុំ?

សុខនៈ មិនដែលចាំរឿងខែរឿងអីទេ ។

វិសាលៈ ប្រហែលអុំ ពេលទៅបាញ់គ្នានៅព្រំដែនហ្នឹងបានរយៈពេលប៉ុន្មានដែរបានគេដកទៅខាងស្វាយរៀង?

សុខនៈ ត្រៀមនៅព្រៃត្បូងហ្នឹងអាកន្លែងដើមដូងហ្នឹង ខ្ទង់ប្រហែលជា២ខែហ្នឹង ចុះព្រោះអីខ្ញុំនៅយុវជនហើយបញ្ចុះបញ្ចូលបានគេឲ្យទៅធ្វើទ័ព ។

វិសាលៈ អញ្ចឹងប្រហែលជាដើម៧៧អុំត្រូវបានគេបញ្ជូនទៅស្វាយរៀង?

សុខនៈ បាទ!

គន្ធី ៖ ទៅស្វាយរៀងហ្នឹងទៅស្រុកណាដែរ?

សុខន ៖ ទៅខេត្តស្វាយរៀងហ្នឹងហ្នង ស្រុកបូពាំហ្នឹង ។

គន្ធី ៖ ស្រុកអីគេដែរ?

សុខន ៖ ស្រុកបូពាំ ខេត្តស្វាយរៀង ។

គន្ធី ៖ ពេលហ្នឹងគេហៅស្រុក...?

សុខន ៖ ស្រុកប្រសូត្រ ស្រុកសំរោង ស្រុកចន្ទ្រា ស្រុកសំរូត ខ្ញុំទៅ៤មុខសញ្ញាហ្នឹង អាហ្នឹងចាំតែប៉ុណ្ណឹង ក្រៅពីហ្នឹងខ្ញុំអត់ដឹងទេ ។

គន្ធី ៖ ហើយទៅដល់នោះធ្វើអីគេដែរ?

សុខន ៖ ទៅធ្វើទាហាន ហើយយើងបាញ់គ្នារហូតហ្នឹង ។

គន្ធី ៖ ចុះប្រជាជននៅភូមិហ្នឹងយ៉ាងម៉េចដែរអុំ?

សុខន ៖ គ្មានប្រជាជនមួយទេ មានតែក្របីងាប់នៅពេញវាលហ្នឹង អត់មានឃើញប្រជាជនទេ មានតែទ័ពហ្នឹង ។

គន្ធី ៖ ម៉េចអញ្ចឹងអុំ?

សុខន ៖ មិនដឹងគេជម្លៀសទៅណាអស់ កន្លែងហ្នឹងសមរភូមិ ។

គន្ធី ៖ គេជម្លៀសអស់?

សុខន ៖ បាទ! ហើយក្របីអីហ្នឹងងាប់អស់ នៅសល់តែឆ្អឹងស្អុយពេញវាលស្រែទាំងអស់ហ្នឹង ហើយខ្ញុំពេលនោះត្រូវគ្រាប់គេឲ្យមកនេះវិញ ហើយមកដេកពេទ្យ មកដេកនៅពេទ្យអ្នកលឿង ហើយមកដេកនៅពេទ្យស្វាយរៀង ហើយមកព្រៃឈរ ហើយមកព្រៃខ្វិត ហើយជិះកប៉ាល់មកភ្នំពេញមក ដល់ពេលមកដល់ភ្នំពេញរាងជាហ្នឹងខ្ញុំមកផ្ទះវិញ ។

វិសាលៈ អត់ទៅវិញទេ?

សុខនៈ អត់ទៅនៅវិញទេ ដល់ពេលហើយទៅនៅកន្លែងនោះដដែលហ្នឹង ដល់ពេលទៅនៅនោះបាន រយៈពេលកន្លះខែបានបែកហ្នឹងមិតអាតាត់អាតាយអស់អាលីង ។

វិសាលៈ ៧/៧ពេលទៅស្វាយរៀងហ្នឹងដែលឮគេនិយាយពីការបោសសំអាតពួកបូព៌ាទេអ៊ំ?

សុខនៈ មិនដឹងម៉េចទេ មិនដែលឮទេ ។

វិសាលៈ ហើយទៅហ្នឹងនៅព្រំដែនរហូត?

សុខនៈ បាទ!

វិសាលៈ មានដែលឮថាគេបញ្ជូនខាងទ័ពខាងនារតីទៅដើម្បីជួយបោសសំអាតខាងបូព៌ាទេ?

សុខនៈ គេហៅយើងទៅហ្នឹង មុនដំបូងទៅនៅជាមួយគ្នា ដល់ហើយបាន យាយម៉ៅ ហ្នឹងគាត់កាន់កង ដែរ ដល់ហើយលោកតា គន់ គីម យើងគាត់ប្រមូលគ្នាគាត់ដាក់មុំ ហើយគ្នាយើងពីខាងនារតី ហ្នឹងដាក់មុំ ដល់ពេលនេះគាត់មិតចូលអញ្ចឹងណា មួយភូមិភាគគាត់ចូលទៅវៀតណាមអញ្ចឹង ណាំ ។

វិសាលៈ មិតហ្នឹងរត់ចូល?

សុខនៈ បាទ! រត់ចូលវៀតណាម ដល់ហើយយួនឡើងមក ហើយចេះតែឆ្ងល់ឈរមើលគេដាក់បុក មុខសញ្ញាពួកយើង មុខសញ្ញាខាងគាត់ ដល់ហើយគាត់ចូលទៅ ហើយពួកខ្ញុំនៅចំហៀងខាង កើតមានអី ដល់ពេលនោះវៃខាងក្រោយ ប្រហែលជា៤-៥ថ្ងៃក្រោយយួនបុកមកទៀតបាន ខ្ញុំត្រូវរបួស ហើយគេបញ្ជូនមកដេកពេទ្យ ដល់ក្រោយៗគេបញ្ជូនរហូតទៅដល់ភ្នំពេញហើយ មកផ្ទះមកព្រោះជាហើយ ។

គន្ធី ៈ បញ្ជូនមកព្យាបាលនៅភ្នំពេញដែរអ៊ំ?

សុខន ៈ បាទ!

គន្ធី ៈ អ៊ំសម្រាននៅណាដែរពេទ្យភ្នំពេញហ្នឹង?

សុខន ៈ មកដេកនៅពេទ្យ៦មករា កាលហ្នឹងគេហៅ៦មករា ។

គន្ធី ៈ នៅមុំណាដែរនៅភ្នំពេញហ្នឹង?

សុខន ៈ ភ្លេចអស់ហើយ វង្វេងវង្វាន់អស់ហើយព្រោះផ្លូវប្លែកអស់ហើយ មិនដឹងនៅមុំណាទេ ដឹង តែនៅខាងជើងវត្តភ្នំ ពេទ្យ៦មករាហ្នឹង កាលហ្នឹងគេដើរបញ្ចោរគ្រប់ក្រុមហើយខ្ញុំចេះតែដើរ ទៅដល់ហើយមកដល់វត្តភ្នំដែរ ។

គន្ធី ៈ ហើយព្យាបាលនៅនោះរយៈពេលប៉ុន្មានដែរអ៊ំ?

សុខន ៖ ខ្ពង់ប្រហែលជាមួយខែ ។

គន្ធី ៖ អ៊ំព្យាបាលដូចថាជូនអ៊ំទៅពេទ្យឬក៏យកអ៊ំទៅណាដែរ?

សុខន ៖ នៅតែក្នុងពេទ្យហ្នឹង ។

គន្ធី ៖ ចុះមានគេបញ្ជូនអ្នកជម្ងឺទៅហ្នឹងច្រើនទេ?

សុខន ៖ មិនខ្វះទេ ដេកពេញពេទ្យ ។

វិសាលៈ សុទ្ធតែទាហាន ឬក៏ប្រជាជន?

សុខនៈ ទាហានខ្លះអញ្ចឹងទៅ ហើយអ្នកយុវជនគ្រុនអញ្ចឹងក៏ទៅដេកនៅពេទ្យភ្នំពេញដែរ ។

វិសាលៈ កាលហ្នឹងរបួសតែត្រង់ជើងមួយទេ ឬក៏មានរបួសកន្លែងណាទៀត?

សុខនៈ របួសតែមួយហ្នឹង ។

វិសាលៈ អ៊ំអាចជួយនិយាយរឿងគ្រោះថ្នាក់ជើងដោយសារមូលហេតុអីបានទេ?

សុខនៈ គ្រោះថ្នាក់ជើងដោយសារខ្ញុំចូលវៃ ហើយដៃគូរជាមួយគ្នាហ្នឹងវាទៅដោះមីន ហើយវាដោះអត់ប្រយ័ត្ន ដល់ហើយផ្ទុះ ។

វិសាលៈ ហើយវៃគ្នាហ្នឹងវៃជាមួយខាងទាហានវៀតណាម?

សុខនៈ បាទ!

វិសាលៈ នៅព្រំដែនស្វាយរៀង?

សុខនៈ នៅព្រំដែនស្វាយរៀង ។

វិសាលៈ ប្រហែលជាឆ្នាំ៧៧?

សុខនៈ បាទ!

វិសាលៈ ហើយបានដេកនៅពេទ្យភ្នំពេញ?

សុខនៈ គេបញ្ជូនយើងមកបន្តៗ ចុះពេទ្យពេលហ្នឹងវាណែនគ្រប់អគារពេកគេចេះតែរុញមក ។

គន្ធី ៖ អញ្ចឹងអ៊ំពេលដែលអ៊ំបានរយៈពេលមួយខែទៅព្យាបាលជាហើយ ជាឬនូវរបួសអ៊ំ?

សុខន ៖ ជាហើយ តែវាជាមិនទាន់ដាច់ វានៅក្រំៗ ហើយខ្ញុំអត់ទៅវិញទេ ។

គន្ធី ៖ គេអត់បញ្ជូនអ៊ំទៅឬអ៊ំសុំគេ?

សុខន ៖ គេបញ្ជូនទៅ តែដល់ពេលគេបញ្ជូនគេសួរយើងហើយ គេសួរថានៅសមរភូមិណា ហើយខ្ញុំកុហកគេថាខ្ញុំនៅសមរភូមិសំបុកមាន់នេះ ដល់ហើយគេឲ្យយើងមកហ្នឹងវិញ បើប្រាប់គេបូព៌ាគេដាក់ឡានបូព៌ាទៅវិញហើយ ប៉ុន្តែខ្ញុំប្រាប់គេថានៅនេះ ។

វិសាលៈ កុហកគេអញ្ចឹង ?

សុខនៈ  បាទ! កុហកគេ ព្រោះនៅនោះវាខ្លាំងពេក នៅនោះវាមាំពេក ។

វិសាលៈ ហើយពេលគេឃើញអ៊ំត្រលប់មកផ្ទះវិញគេមានសួរទេ?

សុខនៈ  ពេលមកដល់ភ្លាមអ្នកដែលនៅជាមួយគ្នាហ្នឹងវាថាម៉េចវិញ  ហើយខ្ញុំក៏ថាពិបាកនិយាយណាស់ គ្មានពេលស៊ីបាយទេ ។

វិសាលៈ វ៉ៃគ្នារហូត?

សុខនៈ  បាទ! ដល់ហើយវាថាគ្រាន់បើ ចេះបានមកវិញ ដល់ពេលមកវិញគេមានឲ្យធ្វើអី ឲ្យតែយើងដាំបាយឲ្យគេស៊ី ឲ្យអាពួកនោះទៅមុខអស់ ហើយខ្ញុំនៅដាំបាយស៊ីម្តង ។

គន្ធី :  ចុះអ៊ំមានប្រសាសន៍ថា មានមេកងស្រីឈ្មោះ ម៉ៅ ។

សុខន : កាលហ្នឹងនៅបូព៌ាឈ្មោះ យាយម៉ៅ ។

គន្ធី :  គាត់ពីខាងណាទៅវិញ?

សុខន : អត់ដឹងទេ មិនដឹងថាគាត់មកពីខាងណាទេ ដឹងតែគាត់ឈ្មោះ យាយម៉ៅ ។

គន្ធី :  គាត់ជាអ្នកនៅខាងបូព៌ាហ្នឹងហ្នងឬក៏មកពីខាងណា?

សុខន : មិនដឹងដែរ ។

គន្ធី :  ហើយអ៊ំម៉េចបានជាស្គាល់ យាយម៉ៅ ហ្នឹង?

សុខន : ពួកគេហៅកង យាយម៉ៅៗ ។

វិសាលៈ កង យាយម៉ៅ ហ្នឹងកងម៉េចទៅ កងខាងបុរសឬក៏កងខាងស្ត្រី?

សុខនៈ  គាត់ខាងកងទ័ពហ្នង គាត់ខាងកាំភ្លើងខ្លីផងហើយខាងកាំភ្លើងវែងផង ស្អេះស្អៀល ហើយគាត់សក់ដូចប្រុសអញ្ចឹង ។

គន្ធី :  តែគាត់កាន់កូនក្រុមគាត់ប្រុសឬស្រី ក្រុមរបស់គាត់?

សុខន : ប្រុសស្រីលាយគ្នាហ្នឹង ។

វិសាលៈ ហើយក្រុមគាត់ហ្នឹងយ៉ាងម៉េចទៅ?

សុខនៈ  ក្រុមគាត់ដូចខ្ញុំថាអញ្ចឹង ដល់ហើយមិតទៅវៀតណាមអស់ទៅ ។

វិសាលៈ អ៊ំ! ដែលអ៊ំមានប្រសាសន៍ថារត់ទៅវៀតណាមហ្នឹង?

សុខនៈ  បាទ!

វិសាលៈ ពេលទៅហ្នឹងមុនដំបូងអ៊ំមានប្រសាសន៍ថាធ្លាប់នៅជាមួយគ្នា ដល់ពេលក្រោយមកអ៊ំមានប្រសាសន៍ខាង គន់ គីម ដែរ?

សុខនៈ  កាលហ្នឹងកងតាហ្នឹងគាត់រត់ទៅវៀតណាមដែរ ដល់ហើយគាត់នៅកាន់ចៅហ្វាយស្រុក តានី ។

វិសាលៈ ហើយគេរត់ទៅហ្នឹងគេរត់តែគ្នាគេបូព៌ាហ្នឹងទេ?

សុខនៈ   បាទ!

វិសាលៈ អត់មានខាងនារតីទៅជាមួយទេ?

សុខនៈ   បាទ! អត់មានទេ ។

វិសាលៈ ហើយអត់មានបានប្រទូសសារ៉ាយគ្នាទេ?

សុខនៈ   អត់មានទេ ។

គន្ធី ៈ   ចុះអ៊ំពេលទៅដល់នោះអត់មានឃើញប្រជាជនមូលដ្ឋានម្នាក់សោះ?

សុខន ៈ អត់មានឃើញទេ ។

គន្ធី ៈ   ចុះអ៊ំមានឆ្ងល់ទេ?

សុខន ៈ មិនដឹងគេយកទៅណាអស់ទេ ប្រជាជននោះ ។

គន្ធី ៈ   មានដឹងទេអ៊ំ?

សុខន ៈ មានតែទ័ពសុទ្ធហ្នង ។

គន្ធី ៈ   ចុះអ៊ំមានដឹង ហើយមានសួរគេទេថាប្រជាជនអត់នៅអញ្ចឹង?

សុខន ៈ អត់មានសួរមានអីទេ ប្រជាជនអត់មានដឹងថាគេជម្លៀសទៅណាទេ ។

គន្ធី ៈ   ហើយអ៊ំមានដឹងថាម៉េចបានគេជម្លៀសទៅទេ?

សុខន ៈ អត់ដឹងទេ ។

គន្ធី ៈ   សុខៗអត់ឃើញមនុស្សហ្នង?

សុខន ៈ បាទ! មានតែទ័ពហ្នងកន្លែងសមរភូមិ ផ្ទះស្រុកហ្នឹងប៉ុនៗណាណី សុទ្ធតែផ្ទះក្បឿង ។

វិសាលៈ អញ្ចឹងពេលដែលអ៊ំត្រលប់មកដល់ក្នុងភូមិវិញ អ៊ំមានប្រសាសន៍ថាអ៊ំនៅដាំបាយរហូត?

សុខនៈ   ដាំបាយតាមកងវិញ ។

វិសាលៈ អាហ្នឹងរោងបាយរួមហ្នឹងមែន?

សុខនៈ   បាយពួកខ្ញុំនៅកងចាស់ហ្នឹង ។

វិសាលៈ ទៅសមរភូមិចាស់វិញ?

សុខនៈ   បាទ!

វិសាលៈ តែទៅអត់កាន់កាំភ្លើងទេ គឺទៅដាំបាយ?

សុខនៈ   ទៅដាំបាយ ។

វិសាលៈ ដាំបាយហ្នឹងគឺគ្រាន់តែដាំទេ ហើយមានអ្នកយកទៅឲ្យទ័ពផ្សេង?

សុខនៈ   មានអ្នកផ្សេងទៀត  ខ្ញុំគ្រាន់តែជាអ្នកចំអិនឲ្យគេទេ ។

វិសាលៈ អញ្ចឹងការហូបចុករបស់អ៊ំប្រហែលជាគ្រប់គ្រាន់ហើយមើលទៅ  បើដាំបាយខ្លួនឯងអញ្ចឹង?

សុខនៈ   គ្រប់គ្រាន់ ។

វិសាលៈ ចុះម្ហូបយ៉ាងម៉េចដែរអ៊ំ?

សុខនៈ   ថ្ងៃណានេះគេធ្វើគោធ្វើជ្រូកអញ្ចឹងណា៎ ។

វិសាលៈ យកទៅឲ្យទាហាន?

សុខនៈ   បាទ!

វិសាលៈ អញ្ចឹងទាហានហ្នឹងមានអាហារគ្រប់គ្រាន់ហើយ?

សុខនៈ   គេដាក់ស្មុកហើយរែកទៅ ។

វិសាលៈ ធ្វើការនៅហ្នឹងរហូតទាល់តែវៀតណាមបុកចូលមកមែន?

សុខនៈ   បាទ!   ខ្ញុំមកបានប្រហែលជា១ខែហ្នឹងបានបុកចូលមកហើយបែកហ្នឹងហ្មង   នាំគ្នាមិតអាគាត់អាគាយហ្នឹង ។

វិសាលៈ អញ្ចឹងអ៊ំត្រូវរបួសប្រហែលឆ្នាំ៨៧ហើយ   ហើយអ៊ំទៅសម្រាននៅពេទ្យ១ខែនៅភ្នំពេញហើយមកធ្វើការនៅនេះបាន២ខែវៀតណាមបុកចូល  អញ្ចឹងត្រូវទេអ៊ំ?

សុខនៈ   អត់បាន២ខែទេ  មិនស្រួលតែមួយខែហ្នឹង ។

វិសាលៈ ខ្ញុំគ្រាន់តែចង់ព្យាយាម   ព្រោះអ៊ំអត់ចាំថ្ងៃខែ   ហើយខ្ញុំចេះតែរាប់ៗជូនអ៊ំណា៎   ព្រោះអ៊ីមុនដំបូងវាវែងឆ្ងាយ  មកពីបែកភ្នំពេញហើយមកនៅហ្នឹងបានមួយឆ្នាំជាងគេឲ្យធ្វើទាហាន  ទាហានជាមួយ  តាអង  បន្ទាប់មកទៀតមកនៅនេះបាន២-៣ខែគេឲ្យទៅព្រំដែននោះ  ដល់ពេលបាញ់គ្នាបានមួយដងបាន   អ៊ំមានប្រសាសន៍ថាមានគេចាត់តាំងអ៊ំឲ្យទៅបូព៌ា   ព្រោះសមរភូមិហ្នឹងវៀតណាមបុកខ្លាំងជាង   ហើយអ៊ំទៅធ្វើហ្នឹងបានគួរសមអញ្ចឹងទៅ   មានពេលច្បាំងមួយនោះអ៊ំក៏ត្រូវរបួសដោយសារតែមិត្តភ័ក្រ្តរបស់អ៊ំដែលជាទាហានហ្នឹង  គាត់ទៅកាន់ខ្សែក្របាញ់ល្ងួសអញ្ចឹងហើយអ៊ំត្រូវរបួសធ្ងន់  ហើយទៅពេទ្យអ្នកលឿង  ហើយបានទៅពេទ្យភ្នំពេញ  ពេទ្យ៦មករានៅខាងជើងភ្នំពេញ   ហើយសម្រាកនោះបានជាងមួយខែហើយបានអ៊ំត្រលប់មកវិញធ្វើការបានប្រហែលជា១-២ខែវៀតណាមបុកចូលពេញប្រទេសតែម្តង?

សុខនៈ   ហ្នឹងអើយ ។

វិសាលៈ អញ្ចឹងហេតុការណ៍កើតឡើងកាលឆ្នាំ៧៨?

សុខនៈ   បាទ!

វិសាលៈ អ៊ំធ្វើកាលឆ្នាំ៧៨ ដល់ពេលគេបាក់ទ័ពមកគេមានរត់មកប្រាប់អ៊ំទេ ហើយអ៊ំរត់ទៅណាមកណា ទៅអ៊ំ?

សុខនៈ គ្មានអ្នកណាប្រាប់យើងទេ ដឹងតែរត់យករួចខ្លួនហើយ អ្នកណាទៅណាទៅៗគ្មានគិតកូនគិតចៅទេ ។

វិសាលៈ កាលហ្នឹងឪពុកម្ដាយនៅរស់ទេ?

សុខនៈ ម៉ែឪខ្ញុំនៅរស់ទេ ទាល់តែចុះមកពីលើទេបានស្លាប់ ។

វិសាលៈ កាលហ្នឹងមានរត់មករកគាត់សិនឬក៏រត់ទៅណាទៀត?

សុខនៈ អត់មានរត់មករកម៉ែឪទេ ម៉ែឪនៅកោះអណ្ដែតហ្នឹង ហើយខ្ញុំនេះចេះតែមិតទៅលើទៅពេលយួនបុកមក ។

វិសាលៈ កាលហ្នឹងលោកយាយលោកតាហើយនឹងបងប្អូន ទៅតែ២នាក់គាត់ទេ ឬក៏បងប្អូនទៅដែរ?

សុខនៈ កាលហ្នឹងទៅតែលោកយាយលោកតា ហើយនឹងប្អូនស្រីមួយ ។

វិសាលៈ កាលហ្នឹងទៅតាំងពីឆ្នាំណាទៅ?

សុខនៈ ខ្ញុំមិនដឹងដែរ ។

វិសាលៈ អ៊ំភ្លេចឆ្នាំហើយ?

សុខនៈ បាទ!

វិសាលៈ ចុះបងប្អូនផ្សេងពេលបាក់ទ័ពមានមកទេ?

សុខនៈ មក តែគេសុទ្ធតែរត់អត់មានជួបគ្នាទេ ។

វិសាលៈ ហើយអ៊ំរត់ដល់ណាខ្លះ ពេលរត់វៀតណាម អ៊ំអាចជួយប្រាប់ខ្ញុំផងបានទេ?

សុខនៈ រត់ទៅដល់ភ្នំស្រុកលើ ។

វិសាលៈ ពីមួយពេលទៅមួយពេលរត់រហូត?

សុខនៈ បាទ! ដើរអញ្ចឹងទៅ ពេលយប់ឡើងដេក ហើយពេលថ្ងៃឡើងដើរទៀតទៅ ។

វិសាលៈ អ៊ំមានចាំទេថារត់ប៉ុន្មានខែ ហើយរត់តាមផ្លូវមានសុទ្ធតែទាហានរត់ដែរ ឬក៏មានតែប្រជាជន?

សុខនៈ មិនដឹងប៉ុន្មានខែទេ រត់ទម្រាំតែទាហានយួនគេតាមទាន់ យើងទាល់ច្រកយើងមកស្រុកវិញហើយ អាហ្នឹងលែងគិតស្លាប់ហើយ ទោះស្លាប់ក៏ស្លាប់ទៅ ។

វិសាលៈ ពេលគេតាមទាន់ហ្នឹងនៅកន្លែងណាទៅ?

សុខនៈ ពេលគេតាមទាន់ហ្នឹងខ្ញុំចុះមកវិញហើយ ហើយពេលតាមទាន់ហ្នឹងខ្ញុំដាក់ចិត្តថាខ្ញុំលែងរត់ហើយ ទៅផ្ទះរកម៉ែរកឪវិញហើយ ខ្ញុំដាក់ចិត្តអញ្ចឹងវិញ ។

វិសាលៈ កន្លែងដាក់ចិត្តហ្នឹងកន្លែងតំបន់ឈ្មោះអីទៅ?

សុខនៈ ខ្ញុំបោះកាំភ្លើងចោលហើយកន្លែងហ្នឹង ។

វិសាលៈ កន្លែងហ្នឹងឈ្មោះអីទៅអ៊ំ?

សុខនៈ ទៅដល់ភ្នំលះបង់ហ្នឹងខ្ញុំបោះកាំភ្លើងចោលហ្នឹង ។

វិសាលៈ កន្លែងហ្នឹងឈ្មោះភ្នំលះបង់ហ្នឹង?

សុខនៈ បាទ! បោះកាំភ្លើងចោលហើយដើរដៃទទេហ្នឹង ។

វិសាលៈ ហើយមានដឹងថាខេត្តអីទេ?

សុខនៈ អត់ដឹងផង ។

វិសាលៈ អ៊ំអត់ដឹងខេត្តអីទៀត?

សុខនៈ នៅកណ្ដាលព្រៃភ្នំហ្នឹង ។

វិសាលៈ អត់មានដឹងថានៅកំពតឬក៏នៅតាកែវអត់ដឹងទេ?

សុខនៈ អត់ដឹងទេ ។

ប្រពន្ធៈ ប្រហែលជាខេត្តកំពង់ស្ពឺ ព្រោះជិតពេជ្រនិល ខាងកើតពេជ្រនិល ។

វិសាលៈ អ៎! កាលហ្នឹងរត់ទៅជាមួយអ៊ំស្រីមែន បានជាអ៊ំស្រីដឹង?

សុខនៈ អត់ទេ កាលហ្នឹងគាត់រត់ទៅដោយឡែកដែរហ្នឹង ។

វិសាលៈ ពេលជួបវៀតណាមគេអត់មានសួរថាធ្លាប់ធ្វើទាហានអីទេ?

សុខនៈ ខ្ញុំដល់ពេលចុះវិញខ្ញុំប្រាប់ក្មួយត្រង់ហ្នឹង ចុះមកជួបវៀតណាម ហើយយើងត្រង់ណា យើងដើរមកតែខ្លួនទទេ ហើយយើងដើរតាមថ្នល់ យើងអត់មានចូលព្រៃទេណា៎ ដល់ពេលមកដល់អត់ទាន់ជួបទេនៅឃាមត្រពាំងក្រឡឹងកំពង់ស្ពឺនេះ យួននៅហ្នឹងគេនៅអមថ្នល់ ហើយគេសួរថាមកពីណា ហើយខ្ញុំថាមកពីលើ ដល់ហើយខ្ញុំប្រាប់ថា អាពត ឡមក ដល់ហើយគេថាល្អ ។

វិសាលៈ អញ្ចឹងគេអត់ធ្វើអីដែរ?

សុខនៈ អត់មានធ្វើអីទេ ហើយខ្ញុំមករហូត សុខសប្បាយរហូតមកអត់មានអ្នកណាចាប់អ្នកណាចងអីទេ ។

វិសាលៈ ហើយដល់ពេលអញ្ចឹងចេះតែដើរមកដល់ស្រុកភូមិទៅ?

សុខនៈ ដើរមកដេកផ្លូវ២យប់បានមកដល់ផ្ទះ ។

វិសាលៈ ហើយពេលមកដល់ផ្ទះឃើញពីណានៅផ្ទះខ្លះអ៊ំ?

សុខនៈ ឃើញតែម៉ែហើយនឹងឪហ្នឹង ។

វិសាលៈ អញ្ចឹងបានន័យថា លោកតាលោកយាយមកពីកោះធំមុនអ៊ំទៀត?

សុខនៈ បាទ! មកពីកោះអណ្តែត ។

វិសាលៈ មកពីកោះអណ្តែត ហើយបងប្អូនវិញមានមកទេ?

សុខនៈ បងប្អូនមកមុន ។

វិសាលៈ នៅជុំគ្នាទាំងអស់ អត់មានអ្នកណាស្លាប់ទេ?

សុខនៈ អត់មានអ្នកស្លាប់ទេ ។

វិសាលៈ ចង់ត្រលប់សុំសួរអ៊ំពីរឿងខាងក្រោយបន្តិច ពីរឿងផ្សេងៗបន្តិចអ៊ំណាស់ ពេលអ៊ំធ្វើនៅកង ឈ្លបមុន៧៥ហ្នឹង ហើយអ៊ំធ្វើឈ្លបហ្នឹងការងាររបស់អ៊ំ គឺនាំអ្នកប្រជាជនទៅធ្វើការកាប់ព្រៃ កាប់អី ហើយអញ្ចឹងការហូបចុកអីអត់អីទេ?

សុខនៈ អត់អីទេ ។

វិសាលៈ ការហូបចុកសមរម្យទេ?

សុខនៈ បាទ!

វិសាលៈ ហើយប្រជាជនអ៊ំនាំទៅធ្វើការហ្នឹងសុទ្ធតែប្រជាជនមូលដ្ឋានឬក៏ប្រជាជន?

សុខនៈ សុទ្ធតែប្រជាជនមូលដ្ឋាន ទៅជាមួយគេយើងក៏ធ្វើ គេក៏ធ្វើ ។

វិសាលៈ អ៊ើ! ធ្វើទាំងអស់គ្នា?

សុខនៈ បាទ! ធ្វើទាំងអស់គ្នា មិនមែនធ្វើតែគេទេ ។

វិសាលៈ នៅក្នុងកងចល័តម៉េញព្វអ៊ំមានប្រសាសន៍ថាមានគេបង្ខំឲ្យរៀបការ ត្រូវទេអ៊ំ?

សុខនៈ អត់ទេ តាប៉ាល់ ហ្នឹងពេលដែលគាត់ការហើយចេញមកនៅជាមួយចាស់ៗ អាប្រធានថ្មីគេធ្វើ បាបខ្ញុំ ។

វិសាលៈ ហើយចង់សុំសួរអ៊ំថា មានដែលឃើញគេចាប់គូរការកាលសម័យខ្មែរក្រហម អ៊ំមានដឹងទេ?

សុខនៈ អត់ដឹងទេ គេចាប់ហ្នឹងព្វតែគូរៗ ។

វិសាលៈ ឃើញឬក៏ព្វ?

សុខនៈ ព្វតែគេនិយាយ ខ្ញុំមិនដែលឃើញទេ ។

វិសាលៈ អញ្ចឹងព្វតែគេនិយាយទេ?

សុខនៈ បាទ!

វិសាលៈ ហើយ តាណាំ ប្រធានកងទ័ពស្រុកហ្នឹង សព្វថ្ងៃគាត់នៅរស់ឬក៏ស្លាប់ហើយ?

សុខនៈ  អត់ដឹងដែរ  គាត់មាឌធំណាស់តាហ្នឹង  ហើយបើអូនឯងចង់សួររកកាពិតទៅសួរម្នាក់ឈ្មោះ
តាសួង១ ហើយម្នាក់ទៀតឈ្មោះ អាមី ធ្វើទ័ពតាំងពី៧០រហូត ។

គន្ធីៈ  តាសួង ហ្នឹងនៅណាដែរអ៊ំ?

សុខនៈ  នៅភូមិហ្នឹងដែរហ្នឹង ។

គន្ធីៈ  នៅម្តុំណាដែរអ៊ំ?

សុខនៈ  នៅកណ្តាលភូមិនេះ ។

គន្ធីៈ  ភូមិអីគេដែរអ៊ំ?

សុខនៈ  នៅភូមិហាន់ទា ហើយ អាមី អីហ្នឹង ។

វិសាលៈ តាមី ហ្នឹងនៅភូមិហ្នឹងដែរ?

សុខនៈ  នៅភូមិហ្នឹងដែរ ហើយទៅមើលចុះ តាសួង ខ្លួនឡើងអាសុះតែមិនស្លាប់ ។

វិសាលៈ ជីវិតគាត់ថ្លៃ ។

សុខនៈ  ហើយទៅពេទ្យឡើងអស់អាលីងហើយ ពេទ្យកាលហ្នឹងថ្នាំគេល្អណាស់ ។

វិសាលៈ ពេទ្យសម័យណាអ៊ំ?

សុខនៈ  ពេទ្យគេថ្នាំគេល្អណាស់ តែជម្ងឺយើងមើលឆាប់ជាណាស់ ។

វិសាលៈ លោកតាមេភូមិដែលធ្លាប់ធ្វើក្រូហ្នឹងមែន មេភូមិហ្នឹងឬក៏មេភូមិណា?

សុខនៈ  មេភូមិហាន់ទាហ្នឹង ។

វិសាលៈ អ៊ំមានប្រសាសន៍ថាឲ្យតែអ្នកនិយាយខុសអីគេយកទៅវ៉ៃចោលក្បែព្រៃ  អាពេលនៅក្នុងភូមិ
ហ្នឹងមានដែលឃើញហេតុការណ៍ហ្នឹងទេ ឬក៏គ្រាន់តែឮ?

សុខនៈ  អត់ដែលទេ ដែលតែនៅធ្វើទ័ពជាមួយគ្នាតែ២នាក់ហ្នឹង ។

វិសាលៈ ហើយអ៊ំថាមានអ្នកនៅដេកជាមួយគ្នាហ្នឹងដេក១គេយកទៅបាត់ទៀត?

សុខនៈ  បាទ! ពេលយកទៅបាត់ ហើយហៅទៅហ្នឹងតែពេលយប់ព្រលប់ទៀត ។

វិសាលៈ កាលហ្នឹងមានដឹងថាពួកគាត់ខុសអីទេ ឬក៏អត់ដឹងទេ?

សុខនៈ  អត់បានដឹងទេ ។

វិសាលៈ ហើយចុះមេឈ្លបនៅហ្នឹងភូមិហ្នឹង  ស្គាល់ទេមេឈ្លបមកយក២-៣នាក់មកយកគេទៅហ្នឹងមាន
ស្គាល់ទេ?

សុខនៈ  មេឈ្លបគេហ្នឹងវាស្លាប់បាត់អស់ហើយ ។

វិសាលៈ ពួកគាត់ស្លាប់បាត់អស់ហើយ?

សុខនៈ   បាទ! វាធ្វើកាចៗពេក និយាយឲ្យខ្ទីគឺកម្មវាហើយ ។

គន្ធីៈ   កាចៗម៉េចទៅអ៊ំ?

សុខនៈ   វាសាហាវអារឿងវៃមនុស្សចោលហ្នឹង ។

គន្ធីៈ   ចុះម៉េចដឹងថាគាត់សាហាវ?

សុខនៈ   គេអ្នកដែលដល់គេហ៊ានវៃមនុស្សគេសាហាវហើយអាហ្នឹង ។

វិសាលៈ ពូគេនិយាយឬក៏បានឃើញផ្ទាល់ភ្នែក?

សុខនៈ   ពូតែគេនិយាយតែមិនដែលបានឃើញផ្ទាល់ភ្នែកទេ ខ្លាចគេញាក់សាច់អស់ហើយ ។

វិសាលៈ សួរថាដែលឃើញគេសម្លាប់មនុស្សទេថាអត់ទេ ចុះបើឃើញគេធ្វើទារុណកម្មមនុស្សអីមានដែលឃើញទេ ទារុណកម្មយ៉ាងម៉េចក៏ដោយឲ្យតែឃើញ?

សុខនៈ   តែនៅកងយុវជនគេធ្វើទារុណកម្មហើយ អាប្រធានហ្នឹងគេខឹងអានោះមួយ ខទារហណ៍ថាខឹងខ្ញុំអញ្ចឹង គេវាស់ឲ្យខ្ញុំ៣០ម៉ែត្រហើយឲ្យខ្ញុំធ្វើឲ្យហើយ ។

វិសាលៈ តែហេតុការណ៍ហ្នឹងកើតឡើងជាក់លាក់ទេ?

សុខនៈ   បាទ!

វិសាលៈ កើតឡើងចំពោះពីណាគេទៅរឿងហេតុការណ៍ហ្នឹង ខបមាថាមេកងស្អប់ហើយចេះតែធ្វើបាបយើងអាហ្នឹងគឺស្រេចចិត្តគេទេ?

សុខនៈ   ស្រេចចិត្តគេទេ ។

វិសាលៈ អ៊ំអាចចាំរឿងពិតប្រាកដបានទេ?

សុខនៈ   និយាយអញ្ចឹងចេះតែបានហើយ និយាយរឿង អាហេង មួយ អាហេង ហ្នឹងនៅយុវជនជាមួយគ្នា អាហេង ហ្នឹងអាយុ១៧ឆ្នាំ ដល់ហើយមិនដឹងពីណាលួចចបគ្នាយកទៅបាត់ទៅហើយថាគ្នានេះឲ្យបាត់ចបបាត់អី ដាក់កំណត់ឲ្យគ្នាដល់ហើយគ្នាភ័យក៏ទៅចងកស្លាប់ទៅ ឲ្យគ្នាកាយអីនៅហ្នឹងដៃ បើគ្នាបាត់ចបហើយមានកាយ អាប្រឡាយនៅខាងត្បូងនេះ ។

គន្ធីៈ   អ្នកណាគេឲ្យកាយហ្នឹងដៃ?

សុខនៈ   ប្រធានគេហ្នឹង ។

វិសាលៈ ឈ្មោះអីទៅ ស្គាល់ទេ?

សុខនៈ   ប្រធាន អាស៊ីម ។

វិសាលៈ គាត់នៅរស់ឬក៏ស្លាប់ហើយ?

សុខនៈ ស្លាប់ហើយ អាស៊ីម ឲ្យគ្នាកាយហ្នឹងដៃហើយគ្នាកាយម៉េចនឹងដាច់ ឲ្យគ្នា៥ម៉ែត្រហើយកាយនឹងដៃ អាហេង ហ្នឹងចង់កនៅអណ្ដូងហ្នឹង ។

គន្ធីៈ ដល់ពេលអញ្ចឹងអ្នកហ្នឹងកាយប៉ុន្មានអត់?

សុខនៈ កាយតែមួយព្រឹក ដល់ពេលហូបបាយហើយគ្នាថាសុំទៅភូមិដើម្បីរកចប ដល់ពេលហើយមានរកចបណាទៅចង់កហ្នឹង ។

គន្ធីៈ អាហ្នឹងឆ្នាំណាដែរអ៊ំ?

សុខនៈ មិនដឹងឆ្នាំណាទេក្មួយ ព្រោះមិនបានចាំ ។

គន្ធីៈ កាលហ្នឹងអ៊ំទៅធ្វើទ័ពហ្នឹងមែន?

សុខនៈ កាលហ្នឹងនៅយុវជនដឹកព្រែកដឹកប្រឡាយជាមួយគ្នាហ្នឹង មិនទាន់ធ្វើទ័ពទេកាលហ្នឹង ។

គន្ធីៈ ហើយនៅហ្នឹងមានគុក មានមន្ទីរសន្តិសុខអីទេ?

សុខនៈ អត់មានទេ ។

គន្ធីៈ ហើយចុះបើមានមនុស្សខុសអីគេយកទៅណាវិញ?

សុខនៈ គេយកទៅគោកគ្រោះ ឃុំរាប ។

គន្ធីៈ គោកគ្រោះហ្នឹងកន្លែងអីគេអ៊ំ?

សុខនៈ គេយកទៅបញ្ចូលនៅហ្នឹង ។

គន្ធីៈ នៅកន្លែងណាវិញ?

សុខនៈ នៅខាងកើតភ្នំ ។

គន្ធីៈ ភូមិឃុំអីដែរ?

សុខនៈ ភូមិរាមអណ្ដើក ឃុំរាមអណ្ដើក ។

គន្ធីៈ អ្នកហ្នឹងដូចថាអ្នករបៀបម៉េច ហើយខុសអីទៅបានគេបញ្ជូនយកទៅហ្នឹងអ៊ំ?

សុខនៈ មិនដឹងដែរក្មួយ មិនដឹងខុសអី កន្លែងគេនៅឃុំឃាំងនៅគុកគេបណ្ដោះអាសន្ន ។

គន្ធីៈ គេហៅគុកដែរនៅនោះ ហើយហៅបណ្ដោះអាសន្ន?

សុខនៈ បាទ!

គន្ធីៈ ហើយគុកហ្នឹងគេមានធ្វើអីខ្លះដែរ អ៊ំមានដឹងពត៌អីខ្លះទេ?

សុខនៈ មិនដឹងទេ មិនដឹងគេដាក់ដៃដាក់ជើងម៉េចមិនដឹងទេ ។

គន្ធីៈ ហើយអ្នកនៅក្នុងភូមិអ៊ំមានដែលត្រូវគេយកទៅដាក់នៅគុកដែរទេ?

សុខនៈ យាយខ្ញុំមួយដែលអន្លុយកៅអីសហ្នឹង ប្ដីគាត់ចុះមកគេឲ្យដេរមួកអីហ្នឹងក្នុងភូមិហ្នឹង គេឲ្យដេរតែមួកហ្នឹងដល់ហើយមិនដឹងម៉េចថាឲ្យគាត់ទៅដេរសុបិន ដល់ហើយយកគាត់ទៅបាត់ មេកងគេដឹកទៅកាលហ្នឹង ។

គន្ធី: ចុះអ៊ំម៉េចដឹងថា នៅហ្នឹងមានគុកមួយ?

សុខនៈ ពួគេនិយាយ ចេះតែនិយាយតាមគេទៅ ។

គន្ធី: ពួគេនិយាយថាម៉េចខ្លះអ៊ំ?

សុខនៈ ពួគេថាមានគុកនៅហ្នឹង ហើយខបមាថាបើយើងទៅធ្វើការនៅកន្លែងហ្នឹងយើងមិនហ៊ានដើរទៅជិតយើងដើរវាងឆ្ងាយព្រោះខ្លាចគេថាយើងទៅយកការណ៍នៅហ្នឹង គ្រាន់តែឃើញពីចម្ងាយកន្ទុះគឺឡូដីអីហ្នឹង ។

គន្ធី: អ៊ំស្គាល់ប្រធានគុកហ្នឹងទេ?

សុខនៈ អត់ទេ ។

គន្ធី: មានដែលពួឈ្មោះខ្លះទេអ៊ំ?

សុខនៈ មិនដែលទេ ។

គន្ធី: អ៊ំពេលដែលពួកខ្ញុំមកសម្ភាសន៍អញ្ចឹងអ៊ំមានអារម្មណ៍យ៉ាងម៉េចដែរអ៊ំ?

សុខនៈ អត់មានអារម្មណ៍យ៉ាងម៉េច គ្រាន់តែថាសម្ភាសន៍ហើយយកខ្ញុំទៅណាទៀត ។

គន្ធី: អត់មានយកទៅណាទេ គ្រាន់តែចង់ដឹងពីប្រវត្តិ អ៊ំអត់មានភ័យខ្លាចអីទេ?

សុខនៈ អត់ភ័យទេ ។

គន្ធី: អ៊ំរាល់ថ្ងៃដែលពួរឿងតុលាការខ្លះទេ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអីមានដែលពួទេ?

សុខនៈ អត់ដែលពួទេ ។

គន្ធី: អត់ដែលពួសោះហ្មង?

សុខនៈ អត់ដែលទេ ។

គន្ធី: ចុះអ៊ំមានដែលទទួលបានសៀវភៅស្វែងរកការពិតទេ?

សុខនៈ ប្អូនទើបតែយកមកមានទាន់បានមើលណា ល្ងាចហើយ ព្រលឹមឡើងមានរវល់ទៅស្រែ ។

គន្ធី: ខ្ញុំឃើញនៅផ្ទះអ៊ំប្រុសហ្នឹងគាត់ កូនគាត់រៀនសៀវភៅប្រវត្តិសាស្ត្រ ហើយកូនអ៊ំមានរៀនសៀវភៅហ្នឹងទេ សៀវភៅហ្នឹងពណ៌ខ្មៅហើយនិយាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបបខ្មែរក្រហម កូនអ៊ំមានទេ?

សុខនៈ  អត់មានទេ ។

គន្ធីៈ  ចុះកូនអ៊ំមានដែលសួរអ៊ំទេ?

សុខនៈ  អារឿងជំនាន់អាពតហ្នឹង?

គន្ធីៈ  ចា៎! ដូចថាបានមើលសៀវភៅហ្នឹងកូនអ៊ំមានបានសួរខ្លះទេ ពីរបបហ្នឹង?

សុខនៈ  វាចេះតែសួរដែរហ្នឹង ថាកាលរបបហ្នឹងម៉េចអីម៉េច?

គន្ធីៈ  សួរម៉េចខ្លះទៅ?

សុខនៈ  សួរថាជំនាន់ហ្នឹងម៉េចទៅឪ អញ្ចឹងណា៎ ហើយខ្ញុំនិយាយប្រាប់វាដូចខ្ញុំបាននិយាយប្រាប់អញ្ចឹងណា៎ ។

គន្ធីៈ  ដល់ពេលនិយាយប្រាប់អញ្ចឹងទៅកូនអ៊ំជឿទេ?

សុខនៈ  ជឿ ។

គន្ធីៈ  ចុះអ៊ំអត់ដែលឮតុលាការហ្នឹងសោះ ដូចថាគេផ្សាយតាមវិទ្យុ ហើយឮតាមគេនិយាយតគ្នាក្នុងភូមិអីមានដែលឮទេអ៊ំ ។

សុខនៈ  អត់ដែលទេ ។

គន្ធីៈ  ហើយកាលឆ្នាំ២០០០ជាងអីអត់ដែលឮដែរ?

សុខនៈ  អត់ ។

គន្ធីៈ  ហើយអ៊ំមានស្គាល់មេដឹកនាំខ្មែរក្រហមអ្នកណាគេខ្លះទេ?

សុខនៈ  ឮតែគេថា ប៉ុល ពត ។

គន្ធីៈ  ហើយមានឮអ្នកណាផ្សេងទៀតទេ?

សុខនៈ  ឮតែគេហៅ ប៉ុល ពតៗ ។

គន្ធីៈ  ហើយក្រៅពីប៉ុល ពត ហ្នឹងមានអ្នកណាគេផ្សេងទេ?

សុខនៈ  អត់ដឹងទេ ។

គន្ធីៈ  ហើយចុះ ខៀវ សំផន, នួន ជា អីអ៊ំមានដែលឮឈ្មោះគាត់ទេ?

សុខនៈ  ឮតែឈ្មោះ តែមិនដែលបានឃើញមុខទេ ។

គន្ធីៈ  ចុះពេលដែលពួកខ្ញុំមកដល់ហ្នឹងអ៊ំមានដឹងពីតុលាការខ្លះទេ ដូចថាមើលសៀវភៅក្រហមអញ្ចឹង?

សុខនៈ  ខ្ញុំទើបតែឃើញពីម្សិលមិញហ្នឹង ។

គន្ធីៈ  អញ្ចឹងជាលើកទីមួយដែលអ៊ំបានឮ?

សុខនៈ	បាទ!  លើកទីមួយហើយ ។

គន្ធីៈ	ចុះអ៊ីមានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលឮថាមានតុលាការខ្មែរក្រហមអញ្ចឹង?

សុខនៈ	ខ្ញុំមានអារម្មណ៍ថា បើសិនជាកើតម្តងទៀតវិញ  តែវាគ្មាននេះទេ ដំណាក់កាលនេះវាអស់ហើយ បើកើតទៀតមិនបាច់ទេរបបហ្នឹង ។

គន្ធីៈ	អ៊ីដែលស្តាប់វិទ្យុទេ?

សុខនៈ	វិទ្យុកាលហ្នឹងមានដែរតែវាខូចខ្ទេចខ្ទីហើយ ។

គន្ធីៈ	ខូចពេលណាដែរ?

សុខនៈ	ខូចរាប់ឆ្នាំហើយ ។

គន្ធីៈ	អត់ដែលបានស្តាប់ទេអ៊ី?

សុខនៈ	អត់ ។

គន្ធីៈ	ហើយទូរទស្សន៍មានដែលមើលទេ?

សុខនៈ	ទូរទស្សន៍មិនដែលទេ  បើទៅមើលទៅមើលតែរឿងកំប្លែងផ្ទះប្អូនហ្នឹង ។

គន្ធីៈ	ចុះពីខាងឃុំខាងអីអញ្ចឹង    ដូចថាខាងពួកខ្ញុំអញ្ចឹងមានចែកទស្សនាវដ្តីស្វែងរកការពិតនេះជារៀងរាល់ខែណាអ៊ី ។

សុខនៈ	ចែករាល់ខែតែមិនដែលឃើញទេ ។

គន្ធីៈ	ខាងពួកខ្ញុំចែកតាមភូមិឃុំណា    មានដែលឮថាពួកអ្នកនៅក្នុងភូមិអ៊ីហ្នឹងនិយាយពីរឿងតុលាការទេ?

សុខនៈ	ដែល ។

គន្ធីៈ	ចុះអ៊ីមានដឹងថាកាត់ទោសពីណាគេខ្លះទេ?

សុខនៈ	អត់ដឹងផង ។

គន្ធីៈ	អត់ដឹងទេ?

សុខនៈ	បាទ!

គន្ធីៈ	ចុះចិត្តអ៊ី    អារម្មណ៍របស់អ៊ីយ៉ាងម៉េចដែរ    ពេលដែលឮតុលាការអញ្ចឹងអ៊ីយល់ថាយ៉ាងម៉េចដែរ?

សុខនៈ	អត់មានយល់ថាយ៉ាងម៉េចទេ ។

វិសាលៈ	គិតថាតុលាការហ្នឹងល្អទេ  មានប្រយោជន៍ទេសម្រាប់សង្គមជាតិខ្មែរយើង  អាចរកយុត្តិធម៌ជូនបងប្អូនខ្មែរយើង  អ្នករងគ្រោះអីហ្នឹង?

សុខនៈ កាល អាពត រឿងការងារវាធ្វើស្អាតស្អំហើយ លុយក៏វាមិនចាយ វាវ៉ៃតែមនុស្សចោល មួយមុខ ហើយនឹងបន្ទត់បាយហ្នឹង ។

គន្ធីៈ ហើយមានដឹងហេតុអីបានជាគេសម្លាប់មនុស្ស ហើយបន្ទត់បាយទេអ៊ំ?

សុខនៈ អត់ដឹងទេ ។

គន្ធីៈ ចុះអ៊ំដឹងថាគេសម្លាប់មនុស្សអញ្ចឹងដែរ?

សុខនៈ ដឹងតែគេសម្លាប់ អ្នកណាខុសគេយកទៅវ៉ៃចោល ដូចវ៉ៃមាន់វ៉ៃត្រីអញ្ចឹងណា៎ ។

គន្ធីៈ ចុះអ៊ំជឿថាអ្នកដែលគេយកទៅវ៉ៃចោលហ្នឹងខុសមែនអត់?

សុខនៈ អ្នកណាទៅដឹងក្មួយអើយ អ្នកណាទៅហ៊ានដឹងរឿងគេ ។

គន្ធីៈ ចុះអ៊ំគិតថាគេសម្លាប់មនុស្សអញ្ចឹងយ៉ាងម៉េចដែរអ៊ំ?

សុខនៈ មិនដឹងម៉េចទេក្មួយអើយ ឲ្យតែគេយកទៅសម្លាប់ចោលហើយ មិនដឹងគ្នាខុសអីមួយ យកគ្នាទៅវ៉ៃចោលនៅ នឹកឃើញអាណិតតែគ្នា ។

គន្ធីៈ ចុះអ៊ំដូចថាក្មេងជំនាន់ក្រោយ ដូចជាកូនរបស់អ៊ំអញ្ចឹង បានរៀនសូត្ររបបខ្មែរក្រហម តើអ៊ំគិតថាយ៉ាងម៉េចដែរ គិតថាវាមានប្រយោជន៍ឬក៏អត់មានទេ?

សុខនៈ ចេះតែប្រាប់ទៅ ។

គន្ធីៈ ហើយអ៊ំគិតថាចង់ឲ្យក្មេងៗរៀនពីរបបហ្នឹងទេ?

សុខនៈ បើគ្រូគេបង្រៀនម៉េចរៀនតាមហ្នឹងទៅ ។

គន្ធីៈ តែបើតាមចិត្តអ៊ំយ៉ាងម៉េច អ៊ំចង់ឲ្យរៀនឬអត់ទេអ៊ំ?

សុខនៈ ខ្ញុំគ្មានចិត្តម៉េចទេ បើវារៀនគឺរៀនហើយ តែលោកគ្រូវាបង្រៀនគឺរៀនហើយ ។

គន្ធីៈ អត់មានយល់ទាស់អីទេ?

សុខនៈ អត់មានយល់ទាស់ទេ ខ្ញុំចំណាស់នេះវាហួសហើយ ។

វិសាលៈ មុននឹងចោទសួរអ៊ំរឿងអ៊ំ អ៊ុំ ហ្នឹង គាត់នៅកងពិសេស ដល់ពេលអញ្ចឹងកងពិសេសអន្តរាគម

គន្ធីៈ លេខប៉ុន្មានដែរកងពលគាត់ អ៊ំមានចាំទេ?

សុខនៈ កងពលជាមួយគ្នា កងពលលេខ២៥០ដូចតែគ្នាហ្នឹង មិនមែន២១០ទេ ។

គន្ធីៈ អញ្ចឹងមិនមែន៤១០ទេ?

សុខនៈ មិនមែនទេ ។

វិសាលៈ អញ្ចឹងអ៊ំនៅកងពលជាមួយគ្នា?

សុខនៈ នៅជាមួយគ្នាតែខុសកងវរយគ្នា ។

វិសាលៈ គាត់កងពិសេស?

សុខនៈ  គេកងពិសេស ។

វិសាលៈ ហើយចុះអ៊ំ?

សុខនៈ  ខ្ញុំនៅកងធម្មតាមិនមែនពិសេសទេ ប៉ុន្តែខ្ញុំនៅកង១១៩ កងពល២៥០ដូចតែគ្នាហ្នឹង ។

វិសាលៈ ហើយគាត់កងពល២៥០ហ្នឹង វរៈត«៦ »?

សុខនៈ  ខ្ញុំមិនចាំទេ ។

វិសាលៈ អញ្ចឹងអ៊ំដឹងថាក្រុមកងរបស់គាត់ហ្នឹងបានឆ្លងទៅវៀតណាម?

សុខនៈ  ពួកហ្នឹងគេវៃគេបានទៅ ។

វិសាលៈ គិតថាអ៊ំ អ៊ូច ហ្នឹងបានទៅវៀតណាមដែរ?

សុខនៈ  មិនដឹងម៉េចទេ ព្រោះគេពិសេសមិនដែលវៃជួបគ្នាផង ។

វិសាលៈ គ្រាន់តែនៅភូមិជាមួយគ្នា?

សុខនៈ  បាទ!

វិសាលៈ អញ្ចឹងខ្ញុំសូមអរគុណពូច្រើនដែលបានផ្តល់ការអនុញ្ញាតឲ្យពួកខ្ញុំបានសម្ភាសន៍ ។

សុខនៈ  បាទ! ហើយដូចខ្ញុំប្រាប់អញ្ចឹង តាញ៉ោង ហើយតាមី ហ្នឹង ។

គន្ធី ៈ  តាញ៉ោង ហើយនឹងតាមី ហ្នឹងនៅណាដែរ?

សុខន ៈ នៅក្នុងភូមិហ្នឹងដែរ តែនៅចុងខាងជើងបន្តិច ។

គន្ធី ៈ  អញ្ចឹងអរគុណច្រើនអ៊ំ?

សុខន ៈ បាទ!

«ចប់»